គណបក្សប្រជាជនកម្ពុជា

មហាសន្និបាតវិសាមញ្ញតំណាងទូទាំងប្រទេស

របស់គណបក្សប្រជាជនកម្ពុជា

ឯករាជ្យ សេរីភាព ប្រជាធិបតេយ្យ

អព្យាក្រឹត និង វឌ្ឍនភាពសង្គម

# សេចក្តីប្រកាសស្តីពី

# កម្មវិធីនយោបាយរបស់គណបក្សប្រជាជនកម្ពុជា

# ដើម្បីកសាង និងការពារមាតុភូមិឆ្នាំ ២០១៣-២០១៨

## បុព្វកថា

គណបក្សប្រជាជនកម្ពុជា (មានឈ្មោះដើមថា បក្សប្រជាជនបដិវត្តន៍ខ្មែរ) ត្រូវបានបង្កើតឡើងនៅថ្ងៃទី២៨ ខែ មិថុនា ឆ្នាំ ១៩៥១ ដោយមានប្រភពចេញពីចលនាតស៊ូដ៏ខ្លាំងក្លារបស់ប្រជាជនកម្ពុជា ប្រឆាំងពួកអាណានិគមនិយមឈ្លានពាន ដើម្បីឯករាជ្យជាតិ ។ ចាប់តាំងពីថ្ងៃបដិសន្ធិរហូតមកដល់បច្ចុប្បន្ន គណបក្សប្រជាជនកម្ពុជាបានរក្សាខ្ជាប់ឥតប្រែប្រួលនូវសារជាតិរបស់ខ្លួន គឺជាតំណាងដ៏បរិសុទ្ធនៃផលប្រយោជន៍ដ៏ឧត្តុង្គឧត្តមរបស់ប្រជាជន តស៊ូពុះពារឆ្លងកាត់រាល់ឧបសគ្គសព្វបែបយ៉ាង ហ៊ានធ្វើពលិកម្មមិនរួញរានៅគ្រប់ដំណាក់កាលនៃប្រវត្តិសាស្ត្រ ដើម្បីឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី សន្តិភាព សេរីភាព អព្យាក្រឹត ប្រជាធិបតេយ្យ វឌ្ឍនភាព និងសុភមង្គលរបស់មាតុភូមិ និងប្រជាជាតិខ្មែរ។ ឆ្លងកាត់ដំណាក់កាលទាំងនោះ មានកម្មាភិបាល យុទ្ធជន យុទ្ធនារីរបស់យើងច្រើនឥតគណនាដែលបានបូជាសាច់ស្រស់ ឈាមស្រស់ និងអាយុជីវិតយ៉ាងអង់អាចក្លាហានបំផុតនៅលើសមរភូមិ ដើម្បីបុព្វហេតុរួមរបស់ជាតិ និងប្រជាជន។

ក្នុងពេលប្រទេសជាតិត្រូវធ្លាក់ទៅក្នុងគ្រោះមហន្តរាយប្រល័យពូជសាសន៍ ដែលរបបកម្ពុជាប្រជាធិបតេយ្យរបស់ពួកប៉ុល ពត បានបង្កឡើងចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ គណបក្សប្រជាជនកម្ពុជា គឺជាកម្លាំងនយោបាយឈានមុខតែមួយគត់ ដែលបានក្រោកឈរតស៊ូបង្កើតឡើងរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា នាថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ១៩៧៨ ដើម្បីប្រមូលកម្លាំងប្រជាជាតិទាំងមូលប្រយុទ្ធផ្តួលរំលំរបបដ៏យង់ឃ្នងនេះ ដោយមានការជួយឧបត្ថម្ភគាំទ្រដ៏ស្មោះសរពីសំណាក់កងទ័ពស្ម័គ្រចិត្តវៀតណាម និងពីកម្លាំងស្នេហាសន្តិភាព យុត្តិធម៌ទាំងឡាយនៅលើសកលលោក រហូតទទួលបានមហាជ័យជំនះជាប្រវត្តិសាស្ត្រនាថ្ងៃ ៧ ខែ មករា ឆ្នាំ ១៩៧៩។ ជ័យជំនះ ៧ មករា បានសង្គ្រោះជាតិឱ្យមានជីវិតរស់ឡើងវិញទាន់ពេលវេលា បញ្ចប់

ដំណាក់កាលដ៏ខ្មៅងងឹតបំផុតដែលពុំធ្លាប់មានក្នុងប្រវត្តិសាស្ត្រនៃកម្ពុជា ហើយនាំប្រទេសជាតិឈានចូលសករាជថ្មីប្រកបដោយពន្លឺ និងក្តីសង្ឃឹម ដែលប្រជាជនបានក្លាយជាម្ចាស់លើជោគវាសនារបស់ខ្លួនយ៉ាងពិតប្រាកដ ។

ក្រោយថ្ងៃជ័យជំនះ ៧ មករា សាធារណរដ្ឋប្រជាមានិតកម្ពុជាដែលជារដ្ឋរបស់ប្រជាជនត្រូវបានបង្កើតឡើង ។ ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជាដែលជាតំណាងស្របច្បាប់តែមួយគត់របស់ប្រជាជនកម្ពុជា បានដឹកនាំស្តារប្រទេសជាតិឡើងវិញពីចំណុចសូន្យ ប្រឹងប្រែងជំនះនូវផលវិបាកដ៏ធ្ងន់ធ្ងរទាំងឡាយដែលរបបប្រល័យពូជសាសន៍ ប៉ុល ពត បានបន្សល់ទុក ក្នុងស្ថានភាពមានតែបាតដៃទទេ និងស្ថិតក្នុងកាលៈទេសៈមានសន្តិភាពផង និងសង្គ្រាមផង ព្រោះត្រូវបន្តប្រយុទ្ធទប់ស្កាត់មិនឱ្យរបបប្រល័យពូជសាសន៍អាចវិលត្រឡប់មកវិញបាន។ មិនតែប៉ុណ្ណោះ សាធារណរដ្ឋប្រជាមានិតកម្ពុជាដ៏ក្មេងខ្ចី ត្រូវទទួលរងការដាក់ទណ្ឌកម្មយ៉ាងអយុត្តិធម៌ពីសំណាក់មជ្ឈដ្ឋានខាងក្រៅមួយចំនួនថែមទៀត ដែលធ្វើឱ្យសភាពការណ៍កម្ពុជានៅគ្រានោះកាន់តែលំបាកស្មុគស្មាញឡើង។

ទោះបីជាមានឧបសគ្គ និងការលំបាកដ៏ធំធេងយ៉ាងនេះក្តី ក៏គ្មានអ្វីអាចមករារាំងដំណើរជាតិកម្ពុជាមិនឱ្យឈានទៅមុខបានឡើយ ។ អាស្រ័យដោយមានមាគ៌ានយោបាយ និងការអនុវត្តដ៏ត្រឹមត្រូវ និងផ្អែកលើកម្លាំងមហាសាមគ្គីជាតិ ព្រមទាំងទទួលបានការជួយឧបត្ថម្ភគាំទ្រពីបណ្តាប្រទេសជាមិត្តជិតឆ្ងាយ និងកម្លាំងជឿនលឿននានា គណបក្សប្រជាជនកម្ពុជាបានដឹកនាំប្រទេសឱ្យចេញផុតពីស្ថានភាពដ៏លំបាកលំបិនបំផុតឈានទៅមុខជាជំហានៗ ឆ្លងពីដំណាក់កាលរីកចម្រើនមួយ ទៅកាន់ដំណាក់កាលរីកចម្រើនមួយទៀតប្រកបដោយមោទនភាព។

សរុបមក រយៈពេល ៣៤ឆ្នាំ កន្លងមកនេះ គណបក្សបានសម្រេចសមិទ្ធផលធំៗជាប្រវត្តិសាស្ត្រយ៉ាង ច្រើនជូនជាតិ និងប្រជាជន គឺ :

**ក. ដំណាក់កាលពីឆ្នាំ ១៩៧៩ ដល់ឆ្នាំ ១៩៩៣ :**

**១.** បានវាយរំលំរបបប្រល័យពូជសាសន៍ប៉ុល ពត ទទួលបានជ័យជំនះជាប្រវត្តិសាស្ត្រនា **ថ្ងៃ ៧ មករា ឆ្នាំ ១៩៧៩** ដែលបានសង្គ្រោះជាតិឱ្យរស់ឡើងវិញទាន់ពេលវេលា ហើយបានប្រយុទ្ធទប់ស្កាត់មិនឱ្យរបបដ៏យង់ឃ្នងនេះអាចវិលត្រឡប់មកវិញបាន ដើម្បីការពារការរស់ឡើងវិញរបស់ប្រជាជាតិ ។

**២.** បាននាំមកជូនប្រជាជនវិញនូវសិទ្ធិ សេរីភាព លទ្ធិប្រជាធិបតេយ្យ កិត្តិយស និងសេចក្តីថ្លៃថ្នូរដែលត្រូវបាត់បង់ទាំងស្រុងក្នុងរបបប៉ុល ពត ។

៣. បានស្តារ និងកសាងសេដ្ឋកិច្ច សង្គមឡើងវិញចាប់ពីលេខសូន្យ ធ្វើឱ្យគ្រប់វិស័យបានរស់ឡើងវិញ ជីវភាពប្រជាជនត្រូវបានស្តារឱ្យមានស្ថិរភាពជាជំហានៗ ហើយបង្កបាននូវបុព្វបទ និងលក្ខណសម្បត្តិជាមូលដ្ឋានបំផុតសម្រាប់ការបន្តស្តារ កសាង និងអភិវឌ្ឍប្រទេសរហូតមកដល់បច្ចុប្បន្ន ។

៤. បានធ្វើជាកម្លាំងស្នូលក្នុងដំណើរការស្វែងរកសន្តិភាព និងការបង្រួបបង្រួមជាតិ រហូតសម្រេចបានកិច្ចព្រមព្រៀងទីក្រុងប៉ារីស ស្តីពីដំណោះស្រាយនយោបាយបញ្ហាកម្ពុជា នាថ្ងៃទី២៣ ខែតុលា ឆ្នាំ ១៩៩១ និងជាកម្លាំងបង្អែកដែលមិនអាចខ្វះបានក្នុងការអនុវត្តកិច្ចព្រមព្រៀងនេះ ព្រមទាំងការបង្កើតរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាទីពីរ ។

**ខ. ដំណាក់កាលពីឆ្នាំ ១៩៩៣-២០១៣ :**

១. បានការពារយ៉ាងគត់មត់នូវរាល់សមិទ្ធផលនៃសង្គមជាតិ ការពាររដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ទប់ស្កាត់ការប៉ុនប៉ងវិលត្រឡប់មកវិញនៃរបបប្រល័យពូជសាសន៍ ថែរក្សាស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សង្គម និងនិរន្តរភាពនៃគ្រប់ស្ថាប័នរដ្ឋ ។

២. បានការពារកម្មសិទ្ធិស្របច្បាប់របស់ប្រជាជន ការពារអាជីពរបស់មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ និងការពាររាល់កិច្ចសន្យាវិនិយោគទុនពីសម័យរដ្ឋកម្ពុជា ។

៣. បានការពារ ពង្រឹង និងពង្រីកលទ្ធិប្រជាធិបតេយ្យសេរី ពហុបក្សនៅកម្ពុជាឱ្យរីកចម្រើនឥតឈប់ឈរ លើកកម្ពស់ការគោរពសិទ្ធិមនុស្ស សមភាពយេនឌ័រ សម្រេចបានការបោះឆ្នោតជាបន្តបន្ទាប់ប្រកបដោយលក្ខណៈសេរី ត្រឹមត្រូវ និងយុត្តិធម៌ ។ ការពារលទ្ធផលនៃការបោះឆ្នោត រក្សាស្ថិរភាពនៃរាជបល្ល័ង្ក និងសម្រេចការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ដែលបានធានាឱ្យប្រទេសជាតិមានស្ថិរភាព និងបន្តឈានទៅមុខយ៉ាងត្រឹមត្រូវតាមគន្លងនៃលទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ ។

៤. បានធ្វើឱ្យទឹកដីទាំងមូលទទួលបានសន្តិភាពពេញលេញ និងការបង្រួបបង្រួមជាតិ ចាប់ពីចុងឆ្នាំ ១៩៩៨ មក តាមរយៈនយោបាយ ឈ្នះ ឈ្នះ ដែលបានធ្វើឱ្យអង្គការចាត់តាំងនៃរបប ប៉ុល ពតត្រូវរលាយទាំងស្រុងទាំងខាងនយោបាយ និងយោធា បញ្ចប់ទាំងស្រុងនូវសង្គ្រាមដ៏រ៉ាំរ៉ៃ ហើយបានធ្វើសមាហរណកម្មប្រជាជនកម្ពុជាដែលបែកបាក់ព្រាត់ប្រាសក្នុងសង្គ្រាមឱ្យបានវិលត្រឡប់មករួមរស់ក្នុងសង្គមជាតិវិញ ប្រកបដោយភាពសុខដុមរមនា មានស្ថិរភាព និងការអភិវឌ្ឍ ។

៥. បានអនុវត្តដោយជោគជ័យនូវកំណែទម្រង់រដ្ឋដ៏ស៊ីជម្រៅ និងទូលំទូលាយ ដែលរួមមាន កំណែទម្រង់រដ្ឋបាលសាធារណៈ ការប្រឆាំងអំពើពុករលួយ កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ កំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់វិមជ្ឈការ និង

វិសហមជ្ឈការ កំណែទម្រង់ជលផល ដីធ្លី ការគ្រប់គ្រងព្រៃឈើ ធនធានធម្មជាតិ និងបរិស្ថានប្រកបដោយនិរន្តរភាព។ បែងចែកដីជូនប្រជាជនដែលគ្មានដី ដើម្បីសង់លំនៅស្ថាន និងបង្កបង្កើនផល លប់ឡូត៍នេសាទទឹកសាបទាំងអស់ ទុកជូនប្រជាជនធ្វើនេសាទជាលក្ខណៈគ្រួសារ និងជាកន្លែងអភិរក្សជលផល ។

**៦**.បានស្តារ និងអភិវឌ្ឍសេដ្ឋកិច្ចឱ្យរីកចម្រើនប្រកបដោយចីរភាព សម្រេចបានកំណើនខ្ពស់ជាបន្តបន្ទាប់ ជំនះបានឆាប់រហ័សនូវឥទ្ធិពលនៃវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុអន្តរជាតិមកលើសេដ្ឋកិច្ចជាតិ ។ ទាក់ទាញ បានអ្នកវិនិយោគឱ្យមកបង្កើតរោងចក្រ សហគ្រាស ធនាគារ មជ្ឈមណ្ឌលពាណិជ្ជកម្ម កសិដ្ឋានសំណង់ធំៗ សេវាកម្មទេសចរណ៍ បង្កើតការងារ មុខរបរ និងចំណូលជូនប្រជាជន។ កសាងសមិទ្ធិលើគ្រប់វិស័យ មានផ្លូវ ស្ពាន អគ្គិសនី ទំនប់ ប្រឡាយ ស្រះទឹក អណ្តូងទឹក មណ្ឌលអភិវឌ្ឍន៍ សាលារៀន មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ មន្ទីរពេទ្យ វត្តអារាម លំនៅស្ថាន ។ល។ ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ច និងធ្វើឱ្យជីវភាពរបស់ប្រជាជនបានប្រសើរឡើងជាលំដាប់ ហើយភាពក្រីក្រត្រូវបានកាត់បន្ថយជាបន្តបន្ទាប់។ កម្ពុជាត្រូវបានវាយតម្លៃថា ជាប្រទេសទី ១៥ លើពិភពលោកដែលសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរយៈពេល ១០ឆ្នាំចុងក្រោយ ជាប្រទេសទី ៥ ក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍន៍ដែលអាចនឹងសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ និងស្ថិតក្នុងចំណាត់ថ្នាក់ទី ១ នៅអាស៊ីប៉ាស៊ីហ្វិកដែលបានសម្រេចវឌ្ឍនភាពល្អប្រសើរក្នុងការកែលម្អសូចនាករផ្នែកសង្គមកិច្ច។

**៧**.បានធ្វើអន្តរាគមន៍ជួយដោះស្រាយទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាពក្នុងការជួយសង្គ្រោះប្រជាជនដែលទទួលរងគ្រោះដោយទឹកជំនន់ គ្រោះរាំងស្ងួត ខ្យល់ព្យុះ និងគ្រោះមហន្តរាយផ្សេងៗទៀត រក្សាបានប្រក្រតីភាពនៃការរស់នៅរបស់ប្រជាជនរងគ្រោះ និងដំណើរការអភិវឌ្ឍន៍។

**៨**.បានកសាងខឿនការពារជាតិរបស់ប្រជាជនយ៉ាងរឹងមាំ ការពារបានគត់មត់នូវអធិបតេយ្យបូរណភាពទឹកដី និងកេរមរតកវប្បធម៌ជាតិរបស់កម្ពុជា ។ ដោះស្រាយបញ្ហាព្រំដែនជាមួយប្រទេសវៀតណាម និងប្រទេសឡាវ ដោយជោគជ័យ សម្រេចការបោះបង្គោលខណ្ឌសីមាព្រំដែនគោកជាមួយប្រទេសទាំងពីរបានជិតរួចរាល់ ហើយបាន និងកំពុងកសាងខ្សែបន្ទាត់ព្រំដែនជាមួយប្រទេសជិតខាងប្រកបដោយសន្តិភាព មិត្តភាព សហប្រតិបត្តិការ និងអភិវឌ្ឍន៍ ។

**៩**.បានសម្រេចជោគជ័យក្នុងការធ្វើសមាហរណកម្មព្រះរាជាណាចក្រកម្ពុជាជាមួយសហគមន៍អន្តរជាតិទាំងក្នុងក្របខ័ណ្ឌអនុតំបន់ តំបន់ និងក្របខ័ណ្ឌអន្តរជាតិ មានទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការល្អជាមួយគ្រប់ប្រទេស ដែលបាននាំមកនូវការគាំទ្រ និងជំនួយឧបត្ថម្ភយ៉ាងច្រើនសម្រាប់ការអភិវឌ្ឍប្រទេសជាតិ ។ ក្នុងឋានៈជាប្រធានអាស៊ាន កម្ពុជាបានធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំកំពូលអាស៊ាន

(ខែមេសា និង ខែវិច្ឆិកា ឆ្នាំ ២០១២) កិច្ចប្រជុំកំពូលអាស៊ីបូព៌ា កិច្ចសន្ទនាអាស៊ានជាសាកលដែលជាលើកទី១ក្នុងប្រវត្តិអាស៊ាន និងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ានពាក់ព័ន្ធផ្សេងទៀត ព្រមទាំងកិច្ចប្រជុំសំខាន់ៗជាច្រើនទាំងក្នុងក្របខណ្ឌតំបន់ និងអន្តរជាតិប្រកបដោយជោគជ័យ ដែលបានឆ្លុះបញ្ចាំងអំពីសមត្ថភាពរបស់កម្ពុជាក្នុងការចូលរួមដោះស្រាយកិច្ចការតំបន់ក៏ដូចពិភពលោក ធ្វើឱ្យកិត្យានុភាព និងកិត្តិនាមរបស់កម្ពុជាកាន់តែត្រូវបានលើកកម្ពស់លើឆាកអន្តរជាតិ ។ ជាមួយគ្នានេះ កម្ពុជាបានចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក និងអង្គការអន្តរជាតិផ្សេងៗទៀត និងបានចូលរួមយ៉ាងសកម្មក្នុងការបំពេញបេសកកម្មថែរក្សាសន្តិភាពនៅប្រទេសមួយចំនួនក្នុងក្របខ័ណ្ឌអង្គការសហប្រជាជាតិ ។ បានធ្វើឱ្យសម្រេចការចុះបញ្ជីប្រាសាទអង្គរវត្ត ប្រាសាទព្រះវិហារ និងសម្បត្តិវប្បធម៌អរូបិយនៃមនុស្សជាតិមួយចំនួនទៀតក្នុងបញ្ជីបេតិកភណ្ឌពិភពលោក និងត្រូវបានជ្រើសរើសឱ្យធ្វើជាម្ចាស់ផ្ទះទទួលរៀបចំកិច្ចប្រជុំគណៈកម្មាធិការបេតិកភណ្ឌពិភពលោកនៅឆ្នាំ ២០១៣ ជាឆ្នាំដែលកម្ពុជាធ្វើជាប្រធាននៃគណៈកម្មាធិការនេះ ។

ឆ្លងតាមបណ្តាសមិទ្ធផលជាប្រវត្តិសាស្ត្រដ៏ថ្លៃថ្លាបំផុតដូចបានបង្ហាញខាងលើនេះ បានឆ្លុះបញ្ចាំងឱ្យឃើញច្បាស់នូវភាពត្រឹមត្រូវទាំងខាងនយោបាយ និងការអនុវត្តរបស់គណបក្សប្រជាជនកម្ពុជាក្នុងការដឹកនាំប្រទេសនៅគ្រប់ដំណាក់កាល ។ ទន្ទឹមនេះ ក៏បានឆ្លុះបញ្ចាំងនូវការគាំទ្រដ៏ទូលំទូលាយរបស់ប្រជាជនកម្ពុជានៅទូទាំងប្រទេសចំពោះគណបក្ស ការខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយ កម្លាំងចិត្តរបស់មន្ត្រីនៅគ្រប់ថ្នាក់គ្រប់ផ្នែក កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និងសមាជិក សមាជិកាគណបក្សក្នុងការបំពេញភារកិច្ចបម្រើប្រទេសជាតិ ព្រមទាំងការជួយឧបត្ថម្ភគាំទ្រដ៏ស្មោះសរ និងមានផលប្រយោជន៍ទៅវិញទៅមករបស់បណ្តាប្រទេសជាមិត្តជិតឆ្ងាយ និងសហគមន៍អន្តរជាតិ ចំពោះបុព្វហេតុដ៏ត្រឹមត្រូវ យុត្តិធម៌របស់ប្រជាជនកម្ពុជា តាំងពីដំណាក់កាលសង្គ្រោះជាតិរហូតមកដល់បច្ចុប្បន្ន ។

**សរុបមករយៈពេល៣៤ឆ្នាំនៃដំណើរជាតិកម្ពុជា បានបញ្ជាក់ច្បាស់ហើយនូវភាពជាម្ចាស់ សមត្ថភាព និងសក្តានុពលរបស់ប្រជាជាតិយើង នៅក្នុងការកសាងប្រវត្តិសាស្ត្ររបស់ខ្លួនប្រកបដោយមោទនភាព ដោយបានប្រែក្លាយទឹកដីកម្ពុជា ពីទឹកដីមរណៈនៅក្រោមរបបប្រល័យពូជសាសន៍ មកជាទឹកដីអភិវឌ្ឍន៍ដ៏រស់រវើក ជាមួយនឹងស្នាមញញឹម និងក្តីសង្ឃឹមរបស់ប្រជាជន ។ បច្ចុប្បន្នប្រជាជនកម្ពុជាកំពុងរស់នៅយ៉ាងសុខដុមរមនា ហើយរួបរួមសាមគ្គីគ្នាជាធ្លុងមួយ ខិតខំបញ្ចេញអស់កម្លាំងកាយ កម្លាំងចិត្តដើម្បីកសាង អភិវឌ្ឍមាតុភូមិ អភិវឌ្ឍមូលដ្ឋានភូមិ ឃុំ សង្កាត់ និងលើកស្ទួយជីវភាពរស់នៅឱ្យកាន់តែប្រសើរឡើង ឈានឆ្ពោះទៅរកអនាគតមួយដ៏រុងរឿង ដែលគ្មានការកើតឡើងជាថ្មីទៀតនូវគ្រោះមហន្តរាយដូចពីអតីតកាល ។**

**ក្នុងគោលបំណងបន្តបំពេញបេសកកម្មបម្រើប្រទេសជាតិ និងប្រជាជនឱ្យបានកាន់តែប្រសើរឡើង គណបក្សប្រជាជនកម្ពុជា សូមប្រកាសកម្មវិធីនយោបាយ ដើម្បីកសាង និងការពារមាតុភូមិ ពីឆ្នាំ ២០១៣ ដល់ឆ្នាំ ២០១៨ ដូចតទៅ ៖**

## I- គោលដៅចំបងជាយុទ្ធសាស្ត្រយូរអង្វែងរបស់គណបក្ស

គណបក្សប្រជាជនកម្ពុជា គឺរបស់ប្រជាជន បានកើតឡើងស្ថិតស្ថេរ និងរីកចម្រើនអាស្រ័យដោយប្រជាជន និងធ្វើអ្វីៗគ្រប់យ៉ាងដើម្បីឧត្តមប្រយោជន៍របស់ជាតិ និងប្រជាជន។ ក្នុងការបំពេញបេសកកម្មជាប្រវត្តិសាស្ត្ររបស់ខ្លួន គណបក្សមានគោលដៅចំបងជាយុទ្ធសាស្ត្រយូរអង្វែងដែលត្រូវពុះពារសម្រេចឱ្យបានគឺ :

- កសាងប្រទេសជាតិឱ្យជឿនលឿន មានវឌ្ឍនភាពខ្លាំងក្លាលើគ្រប់វិស័យ មានសាមគ្គីភាពរឹងមាំ មានការគោរពសិទ្ធិមនុស្ស តម្លៃសីលធម៌ សមធម៌ សេរីភាព និងយុត្តិធម៌ មានលទ្ធិប្រជាធិបតេយ្យដែលចាក់គ្រឹះរឹងមាំ ធ្វើឱ្យប្រជាជនបានរស់នៅប្រកបដោយសុភមង្គល សុខដុមរមនា ទាំងក្នុងគ្រួសារ ទាំងក្នុងសហគមន៍ ក៏ដូចក្នុងសង្គមជាតិទាំងមូល។

- ការពារប្រទេសជាតិឱ្យស្ថិតស្ថេរគង់វង្សក្នុងឯករាជ្យ សន្តិភាព អធិបតេយ្យ និងបូរណភាពទឹកដីដ៏ពេញលេញរបស់ខ្លួន ថែរក្សារដ្ឋធម្មនុញ្ញ និងរាល់សមិទ្ធផលនៃសង្គមជាតិ លើកតម្កើងកិត្យានុភាពជាតិឱ្យបានខ្ពស់ឡើងជានិច្ច ។

## II- គោលការណ៍គ្រឹះនៃកម្មវិធីនយោបាយរបស់គណបក្ស

ឆ្ពោះទៅរកគោលដៅចម្បងជាយុទ្ធសាស្ត្រខាងលើនេះ ក្នុងដំណាក់កាល ពីឆ្នាំ ២០១៣-២០១៨ គណបក្សកំណត់គោលការណ៍គ្រឹះ **១១** ចំណុច គឺ :

**១.** សាមគ្គីប្រជាជាតិទាំងមូល ដោយមិនបែងចែកអំពីនិន្នាការនយោបាយ អតីតកាល ភេទ ជំនឿសាសនា ដើមកំណើតជាតិ និងឋានៈក្នុងសង្គមឡើយ លើមូលដ្ឋានគោរពប្រតិបត្តិខ្ជាប់ខ្ជួននូវរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងបាវចនា ជាតិ សាសនា ព្រះមហាក្សត្រ ដើម្បីថែរក្សា ពង្រីករាល់សមិទ្ធផលដែលសម្រេចបានតាំងពីថ្ងៃជ័យជំនះ៧មករា និងធានាជោគជ័យក្នុងដំណើរការកសាង និងការពារមាតុភូមិតទៅមុខទៀត។

**២.** កសាង ពង្រឹងខឿនការពារជាតិរបស់ប្រជាជនដែលមានកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទជាស្នូលដ៏រឹងមាំ និងមានការគាំទ្រយ៉ាងសកម្មពីប្រជាជន ដើម្បីការពារសន្តិភាព ការពារឯករាជ្យ អធិបតេយ្យ និងបូរណភាពទឹកដីកម្ពុជានៅគ្រប់កាលៈទេសៈ។ ការពាររឹងមាំខឿនសន្តិសុខជាតិ ទប់ស្កាត់ បង្ក្រាបបទឧក្រិដ្ឋ

គ្រប់ប្រភេទ និងរាល់អំពើល្មើសច្បាប់ឱ្យមានប្រសិទ្ធភាពខ្ពស់ រក្សាស្ថិរភាព សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពភូមិ ឃុំ ឱ្យរឹងមាំ ដើម្បីការពារជីវភាពដ៏សុខសាន្តរបស់ប្រជាជន លើកកម្ពស់សេចក្តីថ្លៃថ្នូររបស់សង្គមជាតិ និងធានាដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម។

**៣.** ការពាររបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ និងប្រព័ន្ធនយោបាយប្រជាធិបតេយ្យសេរី ពហុបក្ស បន្តពង្រឹង ពង្រីកលទ្ធិប្រជាធិបតេយ្យទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឱ្យកាន់តែរឹងមាំ ស្របទៅនឹងសំណូមពរនៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ។ បន្តកសាងពង្រឹងនីតិរដ្ឋប្រកបដោយប្រព័ន្ធច្បាប់គ្រប់គ្រាន់ មានការអប់រំផ្សព្វផ្សាយច្បាប់ទូលំទូលាយ មានការអនុវត្តច្បាប់ត្រឹមត្រូវ និងមានប្រសិទ្ធភាព ធានាសមភាព និងយុត្តិធម៌សម្រាប់មនុស្សគ្រប់រូបចំពោះមុខច្បាប់ ។ រាំងស្កាត់រាល់ទម្រង់នៃការប្រើប្រាស់សិទ្ធិអំណាចបំពានលើច្បាប់ និទ្ទណ្ឌភាព និងអំពើហិង្សាគ្រប់រូបភាព។

**៤.** គាំទ្របេក្ខភាពសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់នីតិកាលទី ៥ នៃរដ្ឋសភា និងនីតិកាលបន្តបន្ទាប់ទៀត។ ប្រកាន់យកគោលការណ៍រៀបចំរាជរដ្ឋាភិបាលចម្រុះជាមួយគណបក្សហ៊្វុនស៊ិនប៉ិច ខិតខំពង្រឹងពង្រីកសហប្រតិបត្តិការដ៏ជិតស្និទ្ធជាមួយគ្រប់កម្លាំងនយោបាយ និងមជ្ឈដ្ឋាននានាក្នុងសង្គមដែលមានឆន្ទៈស្នេហាជាតិពិតប្រាកដ ដើម្បីប្រមូលកម្លាំងកសាង និងការពារមាតុភូមិ ។

**៥.** ការពារ និងលើកស្ទួយសិទ្ធិសេរីភាពគ្រប់យ៉ាងរបស់ប្រជាពលរដ្ឋ ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ សេចក្តីថ្លែងការណ៍ជាសកលរបស់អង្គការសហប្រជាជាតិ ព្រមទាំងកតិកា និងអនុសញ្ញាអន្តរជាតិនានាស្តីពីសិទ្ធិមនុស្ស ជាអាទិ៍ សិទ្ធិមានជីវិតរស់នៅ សិទ្ធិប្រកបរបរចិញ្ចឹមជីវិត សិទ្ធិធ្វើនយោបាយ សិទ្ធិបញ្ចេញមតិ សេរីភាពខាងសារព័ត៌មាន សេរីភាពខាងជំនឿសាសនា សិទ្ធិបង្កើតសហជីព និងអង្គការវិជ្ជាជីវៈនានា ។ល។ ប្រជាជនម្នាក់ៗទទួលបានពីរដ្ឋប្រកបដោយសមធម៌នូវផលប្រយោជន៍ខាងសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ អប់រំ សុខាភិបាល និងសេវាសាធារណៈផ្សេងៗទៀត។ កិច្ចសហប្រតិបត្តិការរវាងរដ្ឋ និងសង្គមស៊ីវិលត្រូវបានយកចិត្តទុកដាក់ពង្រឹង ពង្រីកដោយឈរលើគោលការណ៍អភិបាលកិច្ចល្អ និងនីតិរដ្ឋ។

**៦.** លើកកម្ពស់ការផ្តល់សេវាសាធារណៈគ្រប់ផ្នែកនៅគ្រប់ថ្នាក់ជូនប្រជាជន និងគ្រប់មជ្ឈដ្ឋានឱ្យបានកាន់តែប្រសើរឡើងទាំងគុណភាព ប្រសិទ្ធភាព និងវិសាលភាព ជាសេវាសាធារណៈដែលនៅកៀកជាមួយប្រជាជន និងទទួលបានការជឿទុកចិត្ត។ ពង្រឹងសមត្ថភាពរបស់មន្ត្រីសាធារណៈក្នុងការផ្តល់សេវាជូនប្រជាជន ប្រកបដោយភាពស្មោះត្រង់ និងការទទួលខុសត្រូវ។ រាំងស្កាត់ និងមានវិធានការម៉ឺងម៉ាត់តាមច្បាប់ ចំពោះមន្ត្រីណាដែលបានប្រព្រឹត្តប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍របស់ប្រជាជន។ បង្កើនវប្បធម៌ និងផ្នត់គំនិតគោរព និងថែរក្សាទ្រព្យសម្បត្តិសាធារណៈ ។

**៧.** បន្តជំរុញដំណើរការនៃកំណែទម្រង់រដ្ឋដ៏ស៊ីជម្រៅ និងទូលំទូលាយរួមមាន : កំណែទម្រង់រដ្ឋបាលសាធារណៈ ការប្រឆាំងអំពើពុករលួយ កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ កំណែទម្រង់ដីធ្លី ជលផល ការគ្រប់គ្រងព្រៃឈើ ធនធានធម្មជាតិ និងបរិស្ថាន ដើម្បីធានាអភិបាលកិច្ចល្អ និងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ប្រកបដោយចីរភាព។

**៨.** ជំរុញការអភិវឌ្ឍសេដ្ឋកិច្ចឱ្យសម្រេចបានកំណើនខ្ពស់ប្រកបដោយចីរភាពក្នុងរយៈពេលវែង លើមូលដ្ឋានកាន់តែទូលាយ និងកាន់តែមានសមត្ថភាពប្រកួតប្រជែងឡើង ទន្ទឹមនឹងការជំរុញសមាហរណកម្មសេដ្ឋកិច្ចកម្ពុជានៅក្នុងតំបន់ រួមចំណែកធ្វើឱ្យសហគមន៍សេដ្ឋកិច្ចអាស៊ានបានសម្រេចនៅឆ្នាំ ២០១៥ ។ អភិវឌ្ឍវិស័យឯកជនដែលជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ច ទាក់ទាញវិនិយោគផ្ទាល់ពីបរទេស និងជំរុញវិនិយោគក្នុងស្រុក ដើម្បីបង្កើនល្បឿនអភិវឌ្ឍន៍ ពិពិធកម្មសេដ្ឋកិច្ច និងការបង្កើតការងារ។ លើកកម្ពស់ការបែងចែកផ្លែផ្កានៃកំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌ បន្តកាត់បន្ថយអត្រាភាពក្រីក្រឱ្យបានលើស ១% ក្នុង១ឆ្នាំ យកចិត្តទុកដាក់កាត់បន្ថយគម្លាតរវាងអ្នកមានចំណូលខ្ពស់ និងអ្នកមានចំណូលទាប រវាងទីក្រុង និងជនបទ ។ បន្តផ្តល់អាទិភាពចំពោះការអភិវឌ្ឍវិស័យអគ្គិសនី ទឹក ផ្លូវ និងធនធានមនុស្ស។ បន្តអនុវត្តការមិនយកពន្ធលើដីធ្លីរបស់កសិករដែលបង្កបង្កើនផលជាលក្ខណៈគ្រួសារ ការបែងចែកដីជូនប្រជាជនដែលគ្មានដីសម្រាប់សង់លំនៅស្ថាន និងបង្កបង្កើនផល និងការរក្សាដែននេសាទទឹកសាបទាំងអស់ទុកសម្រាប់ប្រជានេសាទធ្វើនេសាទជាលក្ខណៈគ្រួសារ និងជាកន្លែងអភិរក្សជលផល ។ រក្សាឱ្យបាននូវស្ថិរភាពប្រាក់រៀល និងថ្លៃទំនិញចាំបាច់សម្រាប់ជីវភាពប្រជាជន។

**៩.** ថែរក្សា និងបន្តពង្រីករាល់សមិទ្ធផលរបស់សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ព្រមទាំងថ្នាក់ដឹកនាំ សមាជិក សមាជិកា គណបក្សប្រជាជនកម្ពុជា និងសប្បុរសជនទាំងឡាយដែលបានកសាងជូនប្រជាជននៅគ្រប់មូលដ្ឋាន ដូចជា ផ្លូវ ស្ពាន ប្រព័ន្ធធារាសាស្ត្រ អគ្គិសនី សាលារៀនគ្រប់កម្រិត មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ មណ្ឌលសុខភាព លំនៅស្ថាន វត្តអារាម ស្រះទឹក អណ្តូងទឹក ជាដើម។ ពង្រឹងរាល់វិធានការដើម្បីកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ជួយអន្តរាគមន៍សង្គ្រោះប្រជាជនដែលត្រូវរងគ្រោះដោយគ្រោះមហន្តរាយផ្សេងៗ ហើយមិនទុកឱ្យប្រជាជនណាម្នាក់ត្រូវដាច់ស្បៀងដោយមិនបានដឹង និងមិនបានដោះស្រាយឡើយ។ បន្តយកចិត្តទុកដាក់ដល់ការអភិវឌ្ឍសហគមន៍នៃប្រជាជនក្រីក្រ។

**១០.** អភិវឌ្ឍវិស័យអប់រំ សុខាភិបាល ការងារ វប្បធម៌ សង្គមកិច្ច ឱ្យឆ្លើយតបនឹងសំណូមពរនៃការជំរុញល្បឿនកសាងជាតិ ការធ្វើឱ្យកាន់តែប្រសើរឡើងនូវគុណភាពនៃការរស់នៅរបស់ប្រជាជន

ព្រមទាំងការលើកកម្ពស់តម្លៃសីលធម៌ និងអត្តសញ្ញាណជាតិ។ បន្តបង្កើនប្រាក់បៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធឱ្យមានជីវភាពបានកាន់តែប្រសើរឡើង ដោយផ្អែកលើកំណើនសេដ្ឋកិច្ច និងភាពទ្រទ្រង់នៃថវិកាជាតិ ធានាការបើកផ្តល់ប្រាក់បៀវត្ស និងរបបគោលនយោបាយឧបត្ថម្ភផ្សេងៗឱ្យមានប្រសិទ្ធភាព និងតម្លាភាព ។ បន្តជំរុញការដំឡើងប្រាក់ឈ្នួល លើកកម្ពស់ជីវភាព និងលក្ខខណ្ឌការងាររបស់កម្មករនិយោជិតនៅតាមរោងចក្រ សហគ្រាស ដោយផ្អែកលើមូលដ្ឋានច្បាប់ការងារ។ ពង្រឹងពង្រីកប្រព័ន្ធសុវត្ថិភាពសង្គម ដើម្បីជួយគាំទ្រដល់ក្រុមជនដែលងាយទទួលរងគ្រោះ។ ពង្រឹងសមធម៌យេនឌ័រ លើកកម្ពស់តួនាទី និងស្ថានភាពរបស់ស្ត្រីក្នុងសង្គម ការពារ លើកស្ទួយសិទ្ធិជាមូលដ្ឋានទាំង៤របស់កុមារ។ ការពារ លើកកម្ពស់សិទ្ធិជនពិការ យកចិត្តទុកដាក់ចំពោះសុខភាពជនចាស់ជរា។ លើកកម្ពស់តួនាទីអតីតយុទ្ធជន និងអ្នកដែលមានគុណបំណាច់ចំពោះជាតិមាតុភូមិ ។ អភិវឌ្ឍយុវជន ទាំងខាងចំណេះដឹង ចំណេះធ្វើ សុខភាពកាយសម្បទា និងសីលធម៌ ឱ្យក្លាយជាកម្លាំងស្នូលបន្តវេនប្រកបដោយថាមពលរបស់ជាតិ។

**១១.** បន្តខិតខំធ្វើការតស៊ូតាមផ្លូវច្បាប់នៅតុលាការយុត្តិធម៌អន្តរជាតិ ដើម្បីឱ្យតុលាការនេះបកស្រាយសាលក្រមឆ្នាំ ១៩៦២ ស្តីពីបូរណភាពដែនដីដែលស្ថិតនៅក្នុងអធិបតេយ្យភាពកម្ពុជានៅតំបន់ប្រាសាទព្រះវិហារ។ បន្តលើកកម្ពស់ការអនុវត្តនយោបាយការបរទេស អព្យាក្រឹត សន្តិសហវិជ្ជមាន និងមិនចូលបក្សសម្ព័ន្ធ ខិតខំកសាងពង្រឹងពង្រីកទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការជាមួយគ្រប់ប្រទេស ដោយឈរលើមូលដ្ឋានស្មើភាព គោរពឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដីនៃប្រទេសនីមួយៗ និងមានផលប្រយោជន៍ទៅវិញទៅមក ដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ក្នុងក្របខ័ណ្ឌទ្វេភាគីជាមួយប្រទេសជាមិត្ត និងក្នុងក្របខ័ណ្ឌអនុតំបន់ តំបន់ និងអន្តរជាតិ។ បន្តបំពេញតួនាទីដ៏សកម្មរបស់កម្ពុជាក្នុងកិច្ចការអន្តរជាតិនានា ជាពិសេសក្នុងការធ្វើសមាហរណកម្មអាស៊ាន ដើម្បីធ្វើឱ្យសម្រេចសហគមន៍អាស៊ានឆ្នាំ ២០១៥ ។ បន្តខិតខំដោះស្រាយបញ្ហាព្រំដែនគោក និងសមុទ្រជាមួយប្រទេសជិតខាងឱ្យបានសម្រេចដោយផ្អែកលើវជ្ជធម្មនុញ្ញ ច្បាប់ជាតិ ច្បាប់អន្តរជាតិ និងលិខិតុបករណ៍អន្តរជាតិនានា ជាពិសេសជំរុញការបោះបង្គោលព្រំដែនជាមួយប្រទេសវៀតណាម ប្រទេសឡាវ ឱ្យបានឆាប់ចប់សព្វគ្រប់ និងជាមួយប្រទេសថៃ ខិតខំបន្តរុករកបង្គោលសីមាចាស់ដែលនៅសេសសល់ឱ្យបានឆាប់ ព្រមទាំងជំរុញឱ្យមានការឯកភាពគ្នាលើទីតាំងបង្គោលដែលបានរកឃើញហើយ ដើម្បីធានានូវអធិបតេយ្យនិងបូរណភាពទឹកដីដ៏ពេញលេញរបស់កម្ពុជា និងកសាងខ្សែបន្ទាត់ព្រំដែនមួយប្រកបដោយសន្តិភាព មិត្តភាព សហប្រតិបត្តិការ និងអភិវឌ្ឍន៍ ។

## III- នយោបាយតាមវិស័យ

### ក. ការការពារជាតិ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ

### ការពារជាតិ

**១.** ពង្រឹងកិច្ចការពារអធិបតេយ្យជាតិនៃព្រះរាជាណាចក្រកម្ពុជាលើដែនដីគោក ដែនកោះ ដែនទឹក-ផ្ទៃក្នុង ដែនសមុទ្រ តំបន់តភ្ជាប់ តំបន់សេដ្ឋកិច្ចផ្តាច់មុខ ខ្ពង់រាបបាតសមុទ្រ និងដែនអាកាស ដោយយកចិត្តទុកដាក់លើការកសាងផែនការយុទ្ធសាស្ត្រការពារជាតិ ពង្រឹងទីតាំងឈរជើងរបស់កងឯកភាពជួរមុខ កសាងទីតាំងបង្អែក ប្រព័ន្ធការពារ ប្រព័ន្ធទំនាក់ទំនងបញ្ជា ប្រព័ន្ធគាំទ្រ ផ្លូវគមនាគមន៍ ។ល។ ដែលជាមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់កិច្ចការពារជាតិ ។ ពង្រឹងការតស៊ូតាមផ្លូវច្បាប់នៅតុលាការយុត្តិធម៌អន្តរជាតិដើម្បីការពារអធិបតេយ្យរបស់កម្ពុជានៅតំបន់ប្រាសាទព្រះវិហារ ។ លើកទឹកចិត្តប្រជាពលរដ្ឋតាំងទីលំនៅកសាងភូមិស្ថានតាមបណ្តោយព្រំដែន ផ្សារភ្ជាប់នឹងការរីតចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការជាមួយប្រទេសជិតខាង ដើម្បីកសាងព្រំដែនជាតំបន់សន្តិភាព សន្តិសុខ សហប្រតិបត្តិការ និងអភិវឌ្ឍន៍ពិតប្រាកដ។

**២.** បន្តអនុវត្តកំណែទម្រង់កងយោធពលខេមរភូមិន្ទឱ្យស្របទៅនឹងការរីកចម្រើនរបស់ប្រទេសជាតិនិងពិភពលោក ជាកងកម្លាំងដែលមានឧត្តមគតិស្មោះត្រង់ដាច់ខាតចំពោះជាតិមាតុភូមិ គោរពស្រឡាញ់ប្រជាជន មានឆន្ទៈប្រយុទ្ធប្តូរផ្តាច់ និងសមត្ថភាពគ្រប់គ្រាន់ក្នុងការការពារឯករាជ្យ សន្តិភាព អធិបតេយ្យបូរណភាពទឹកដី និងរាល់សមិទ្ធផលនៃសង្គមជាតិបានរឹងមាំ ហើយចូលរួមសកម្មក្នុងដំណើរការអភិវឌ្ឍន៍ប្រទេសជាតិ។

**៣.** បន្តអភិវឌ្ឍធនធានមនុស្សក្នុងវិស័យការពារជាតិ តាមរយៈការបង្កើនគុណភាពហ្វឹកហ្វឺននៅតាមបណ្តាសាលាហ្វឹកហ្វឺន ពង្រឹងសមត្ថភាពយោធាចារ្យ កសាងជួរនាយទាហានវ័យក្មេងដែលជ្រើសចេញពីសិស្សនិស្សិត និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសជាមិត្ត ដើម្បីពង្រីកកម្មវិធីបណ្តុះបណ្តាលយោធិនអាជីព។ ពង្រឹងខ្សែរយៈចាត់តាំងក្នុងជួរកងទ័ពនៅគ្រប់ថ្នាក់ ដើម្បីធានាប្រសិទ្ធភាពនៃការគ្រប់គ្រងកងកម្លាំង។ លើកកម្ពស់សុខុមាលភាពកងទ័ព ធានាការផ្គត់ផ្គង់ភ័ស្តុភារ ហិរញ្ញវត្ថុ និងសម្ភារៈបច្ចេកទេសគ្រប់ប្រភេទដល់កងទ័ពឱ្យបានល្អប្រសើរ ជាពិសេសចំពោះបណ្តាកងឯកភាពឈរជើងនៅខ្សែត្រៀមជួរមុខនិងកងការពារដែនកោះ។

**៤.** ពង្រឹងពង្រីកទំនាក់ទំនង និងសហប្រតិបត្តិការអន្តរជាតិសម្រាប់ការអភិវឌ្ឍកងយោធពលខេមរភូមិន្ទលើគ្រប់ផ្នែក និងបន្តចូលរួមក្នុងបេសកកម្មរក្សាសន្តិភាពលើពិភពលោកក្នុងក្របខ័ណ្ឌកងកម្លាំងរក្សាសន្តិភាពនៃអង្គការសហប្រជាជាតិ។

## សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

**៥.** ការពារសន្តិសុខជាតិ ប្រឆាំងដាច់ខាតរាល់អំពើដែលនាំទៅដល់ការបង្កអស្ថិរភាពនយោបាយ ការបង្កជម្លោះប្រដាប់អាវុធក្នុងជាតិ ឬជាមួយប្រទេសជិតខាង និងមិនអនុញ្ញាតឱ្យមានការប្រើប្រាស់ទឹកដីកម្ពុជាដើម្បីប្រឆាំងនឹងប្រទេសជិតខាង ។ បង្ការដាច់ខាតមិនឱ្យកើតមានការគំរាមកំហែង ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ អាយុជីវិត ឬមហន្តរាយ ដែលបង្កឡើងដោយអំពើភេរវកម្ម។

**៦.** ពង្រឹងវិធានការគ្រប់គ្រងសង្គម ដោយគួបផ្សំនឹងការបង្កើនកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសក្នុងតំបន់ និងពិភពលោក ដើម្បីបង្ការ ទប់ស្កាត់ និងបង្ក្រាបមិនឱ្យមានក្រុមសង្គមងងឹតកើតមាននៅកម្ពុជា។ យកចិត្តទុកដាក់ស្រាវជ្រាវ ស៊ើបអង្កេត មិនទុកឱ្យមានខ្សែរវាយៈនៃបណ្តាញឧក្រិដ្ឋជនឆ្លងដែនធ្វើសកម្មភាពបាន ឬប្រើប្រាស់កម្ពុជាជាភូមិសាស្ត្រគេចខ្លួនពីសំណាញ់ច្បាប់នៃប្រទេសក្រៅ។

**៧.** លើកកម្ពស់ចលនាមហាជនចូលរួមការពារសន្តិសុខ សុវត្ថិភាព នៅមូលដ្ឋានឱ្យបានក្លៀវក្លា ដើម្បីពង្រឹងខឿនសន្តិសុខជាតិឱ្យកាន់តែរឹងមាំ តាមរយៈការបន្តជំរុញចលនាអនុវត្តគោលនយោបាយ "ភូមិ ឃុំ មានសុវត្ថិភាព" ឱ្យមាននិរន្តរភាព និងសកម្មនៅគ្រប់មូលដ្ឋានទូទាំងប្រទេស។ ពង្រឹងវិធានការទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រហ្មទណ្ឌគ្រប់ប្រភេទ ជាពិសេសអំពើប្លន់ ឃាដកម្ម អំពើហិង្សាដោយចេតនា ការជួញដូរគ្រឿងញៀន ការជួញដូរមនុស្ស និងសកម្មភាពជនទំនើង។ ល។ ដើម្បីបង្កភាពកក់ក្តៅក្នុងការរស់នៅ និងប្រកបមុខរបររបស់ប្រជាជន ។

**៨.** ខិតខំរៀបចំសណ្តាប់ធ្នាប់សាធារណៈឱ្យបានល្អប្រសើរ ស្របតាមស្ថានភាពប្រទេសជាតិដែលកំពុងមានការរីកចម្រើន ដោយយកចិត្តទុកដាក់គ្រប់គ្រងកត្តាជាមូលដ្ឋាននានាក្នុងការធានាសណ្តាប់ធ្នាប់ សុវត្ថិភាពសង្គម ដូចជា ជំរុញការរៀបចំសណ្តាប់ធ្នាប់ និងកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ ការងារគ្រប់គ្រងអាវុធជាតិផ្ទុះ ការគ្រប់គ្រងមុខរបរពិសេស ការងារផ្តល់អត្តសញ្ញាណប័ណ្ណ ការបង្ការ និងពន្លត់អគ្គិភ័យ ។ល។

**៩.** ពង្រឹងការគ្រប់គ្រងជនបរទេសគ្រប់ប្រភេទនៅកម្ពុជា មិនទុកឱ្យមានមុខសញ្ញាគ្រោះថ្នាក់ ឬមុខសញ្ញាហាមឃាត់នានាអាចជ្រៀតចូលបាន ។ បន្តជំរុញការដោះស្រាយបញ្ហាជនបរទេសអន្តោប្រវេសន៍ និងគ្រប់គ្រងជនអន្តោប្រវេសន៍ឱ្យមានប្រសិទ្ធភាព ព្រមទាំងដោះស្រាយអំពើល្មើសច្បាប់របស់ជនបរទេសយ៉ាងម៉ឺងម៉ាត់តាមច្បាប់ជាតិ និងអន្តរជាតិ ។

**១០.** លើកកម្ពស់សមត្ថភាពបំពេញភារកិច្ចរបស់កងកម្លាំងនគរបាលជាតិឱ្យកាន់តែមានវិជ្ជាជីវៈប្រកបដោយប្រសិទ្ធភាព ការទទួលខុសត្រូវ សីលធម៌ គុណធម៌ ក្លាយជាស្ថាប័នបម្រើប្រជាជនដ៏ស្មោះត្រង់ និងជាបង្អែកជាទីទុកចិត្តកក់ក្តៅរបស់សង្គមជាតិ។

## ២- ការពង្រឹងរដ្ឋបាលសាធារណៈ វិមជ្ឈការ វិសហមជ្ឈការ ការពង្រឹងផ្នែកច្បាប់ និងប្រព័ន្ធ យុត្តិធម៌ និងការប្រឆាំងអំពើពុករលួយ :

**១១-** បន្តអនុវត្តកំណែទម្រង់រដ្ឋបាលសាធារណៈ សំដៅធ្វើឱ្យរដ្ឋបាលសាធារណៈកាន់តែមានភាពឆ្លើយតប ប្រសិទ្ធភាព ប្រសិទ្ធផល និងជំនឿទុកចិត្ត ហើយលើកកម្ពស់វប្បធម៌សេវាសាធារណៈ ឆន្ទៈម្ចាស់ការ ភក្តីភាព និងមនសិការវិជ្ជាជីវៈរបស់មន្ត្រីរាជការ ដើម្បីប្រែក្លាយរដ្ឋបាលសាធារណៈទៅជាអ្នកផ្តល់សេវាសាធារណៈដ៏មានប្រសិទ្ធភាព ដែលបម្រើប្រជាជនបានកាន់តែល្អប្រសើរឡើង។ គណបក្សនឹងបន្តផ្តោតលើការអនុវត្តយុទ្ធសាស្ត្រទាំង ៣ នៃកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលគឺ : ១-ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ តាមរយៈការបង្កើត និងដាក់ឱ្យអនុវត្តស្តង់ដារសេវាសាធារណៈ , ២-ការអភិវឌ្ឍសមត្ថភាព ការកែលម្អការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស តាមរយៈការបង្កើត និងដាក់ឱ្យអនុវត្តគោលនយោបាយធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ និងប្រព័ន្ធគ្រប់គ្រងគុណផលការងារ , និង៣-ការកែទម្រង់ប្រព័ន្ធបៀវត្ស និងប្រាក់បន្ថែមផ្សេងៗដើម្បីពង្រឹងប្រសិទ្ធភាពការងារ ព្រមទាំងការពង្រឹងការគ្រប់គ្រងក្របខ័ណ្ឌ និងការពង្រាយមន្ត្រីរាជការស៊ីវិល។

**១២-** បន្តអនុវត្តឱ្យបានកាន់តែស៊ីជម្រៅបន្ថែមទៀត នូវកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ បន្តពង្រឹងរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់ថ្នាក់អំពីស្ថាប័ន ប្រព័ន្ធគ្រប់គ្រងអភិវឌ្ឍធនធានមនុស្ស ការផ្ទេរមុខងារ និងធនធាន ប្រព័ន្ធថវិកាហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ ការកសាងសមត្ថភាព សំដៅធានាឱ្យរដ្ឋបាលគ្រប់ថ្នាក់នៅថ្នាក់ក្រោមជាតិបំពេញការងារដោយមានការចូលរួម គណនេយ្យភាព តម្លាភាព និងការឆ្លើយតប ក្នុងការផ្តល់សេវាសាធារណៈ ការអភិវឌ្ឍមូលដ្ឋាន និងការចូលរួមកាត់បន្ថយភាពក្រីក្រ ដើម្បីរួមចំណែកប្រកបដោយប្រសិទ្ធភាពក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម របស់ប្រទេសជាតិប្រកបដោយនិរន្តរភាព ។

**១៣-** បន្តអនុវត្តឱ្យកាន់តែស៊ីជម្រៅកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ សំដៅជំរុញការរៀបចំក្របខ័ណ្ឌច្បាប់ឱ្យមានស្ថិរភាព និងកាន់តែទទួលបានការជឿទុកចិត្ត ព្រមទាំងពង្រឹងសមត្ថភាព ឯករាជភាព និងភាពមិនលំអៀងនៃស្ថាប័នតុលាការដែលជាកត្តាដ៏សំខាន់នៃដំណើរការពង្រឹងនីតិរដ្ឋ ការបែងចែកអំណាចដាច់ពីគ្នា ការគោរពសិទ្ធិបុគ្គល និងការធានាភាពយុត្តិធម៌សម្រាប់ប្រជាជនទូទៅ។ ដើម្បីសម្រេចទិសដៅនេះ បណ្តាសកម្មភាពសំខាន់ៗនឹងត្រូវបន្តជំរុញយ៉ាងសកម្ម ជាអាទិ៍ សម្រាប់កំណែទម្រង់ច្បាប់ គឺជំរុញការកសាងច្បាប់ថ្មីៗតាមការចាំបាច់នៃការគ្រប់គ្រងរដ្ឋ និងស្របតាមដំណើរការបង្កើតសហគមន៍អាស៊ាននឆ្នាំ ២០១៥ ការពង្រឹងការអនុវត្តច្បាប់នានាជាធរមានឱ្យកាន់តែមានប្រសិទ្ធភាព ការបង្កើនការអប់រំផ្សព្វផ្សាយ និងបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់គ្រប់ថ្នាក់ និងប្រជាជនឱ្យបានទូលំទូលាយក្នុងវិស័យច្បាប់ ។ សម្រាប់

កំណែទម្រង់ប្រព័ន្ធយុត្តិធម៌ គឺការជំរុញការកសាងច្បាប់ពាក់ព័ន្ធនឹងស្ថាប័នតុលាការ ជាអាទិ៍ ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា និងវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។ ដើម្បីឱ្យការដោះស្រាយរឿងក្តីតាមនីតិវិធីជាធរមានបានកាន់តែឆាប់រហ័ស និងប្រកបដោយយុត្តិធម៌ គណបក្សនឹងបន្តជំរុញការពង្រឹងស្ថាប័នតុលាការ និងអយ្យការ តាមរយៈការខិតខំបង្កើនសមត្ថភាពរបស់ចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីតុលាការ និងជំរុញបង្កើតរដ្ឋបាលតុលាការតាមសាលាជម្រះក្តី គ្រប់ជាន់ថ្នាក់។ ជាមួយគ្នានេះដែរ ក្រមសីលធម៌ មនសិការវិជ្ជាជីវៈ និងវិន័យ នឹងត្រូវពង្រឹងតាមរយៈការបណ្តុះបណ្តាលបឋម និងការបណ្តុះបណ្តាលបន្តនៅរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ហើយនិងការចុះធ្វើអធិការកិច្ចនៅតាមសាលាជម្រះក្តីរបស់អង្គភាពអធិការកិច្ចនៃក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។ បន្តជំរុញការពង្រឹងយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដើម្បីកាត់បន្ថយចំនួនសំណុំរឿងដែលមិនចាំបាច់ក្នុងតុលាការ និងកាត់បន្ថយភាពស្មុគស្មាញក្នុងសង្គម។ បន្តជំរុញការកសាងអគារ និងបំពាក់សម្ភារៈសម្រាប់សាលាជម្រះក្តីឱ្យមានស្តង់ដារ ដើម្បីផ្តល់លទ្ធភាពទទួលបានយុត្តិធម៌សម្រាប់ប្រជាជនគ្រប់រូប។

**១៤.** ប្រកាន់ខ្ជាប់ជំហរម៉ឺងម៉ាត់ក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ តាមរយៈការពង្រឹង និងបង្កើនប្រសិទ្ធភាពនៃវិធានការស្នូលទាំង ៣ គឺ : ការអប់រំដើម្បីឱ្យម្នាក់ៗ ទាំងអ្នកដើមចម និងអ្នកទទួលផលមិនប្រព្រឹត្តអំពើពុករលួយ , ការបង្ការ និងទប់ស្កាត់ ដើម្បីឱ្យម្នាក់ៗមិនអាចប្រព្រឹត្តអំពើពុករលួយ , និងការបង្ក្រាបបទល្មើស បញ្ជូនទៅតុលាការ ដើម្បីឱ្យម្នាក់ៗមិនហ៊ានប្រព្រឹត្តអំពើពុករលួយ ។ លើមូលដ្ឋាននេះទើបធានាបាននូវការលើកកម្ពស់ប្រសិទ្ធភាពនៃសេវាគ្រប់បែបយ៉ាង ពង្រឹងអភិបាលកិច្ចល្អ និងនីតិរដ្ឋ ព្រមទាំងរក្សាភាពស្អាតស្អំ និងយុត្តិធម៌របស់មន្ត្រីដែលជាកត្តាចាំបាច់ក្នុងការអប់រំខ្លួន សង្គមជាតិ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។ ដើម្បីបំបាត់ឱកាស និងរារាំងអំពើពុករលួយ ចាំបាច់ត្រូវបន្តអនុវត្តឱ្យបានសកម្ម និងមានលទ្ធផលខ្ពស់ក្នុងការលុបបំបាត់ការយកកម្រៃសេវាខុសច្បាប់នៅរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់ថ្នាក់ នៅក្រសួង ស្ថាប័ន មន្ទីរ និងការិយាល័យនានា គឺគ្មានការទារលុយតាមកន្លែងធ្វើការ តាមផ្សារ តាមដងផ្លូវ តាមដងទន្លេ ឬច្រកព្រំដែនឡើយ។

**គ. ការអភិវឌ្ឍសេដ្ឋកិច្ច :**

**ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ**

**១៥.** បន្តរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាពក្នុងបរិការណ៍អតិផរណាមានកម្រិតទាប និងអាចគ្រប់គ្រងបាន ហើយអត្រាប្តូរប្រាក់មានស្ថិរភាព ដើម្បីធានាបរិស្ថានអនុគ្រោះ

សម្រាប់ការអភិវឌ្ឍ និងការសម្រេចគោលដៅធំៗនៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ការលើកកម្ពស់ជីវភាពរបស់ប្រជាជន ព្រមទាំងសមាហរណកម្មទៅក្នុងតំបន់ និងពិភពលោក ។ ក្នុងគោលដៅនេះ គណបក្សខិតខំសម្រេចឱ្យបានកំណើនសេដ្ឋកិច្ចជាមធ្យម ៧% ក្នុងមួយឆ្នាំ ដើម្បីធ្វើឱ្យកម្ពុជាអាចចាកចេញផុតពីប្រទេសមានចំណូលទាប ឈានឡើងជាប្រទេសមានចំណូលមធ្យមកម្រិតទាប យ៉ាងយូរនៅឆ្នាំ២០១៨ និងក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០។ ជាមួយគ្នានេះ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ឆ្នាំ ២០១៥ របស់កម្ពុជា និងគោលដៅកាត់បន្ថយអត្រានៃភាពក្រីក្រជាង ១%ក្នុងមួយឆ្នាំក៏ត្រូវសម្រេចឱ្យបាន និងខិតខំរួមចំណែកធ្វើឱ្យសម្រេចគោលដៅសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ ២០១៥។ ការរីកចម្រើនខាងសេដ្ឋកិច្ចត្រូវតែធានានូវកាលានុវត្តភាព ការចូលរួម និងការទទួលផលដោយសមធម៌ សម្រាប់ប្រជាពលរដ្ឋគ្រប់ស្រទាប់។

**១៦.** បន្តអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈសមស្រប គួបផ្សំនឹងគោលនយោបាយរូបិយវត្ថុដ៏ប្រយ័ត្នប្រយែងប្រកបដោយប្រសិទ្ធភាព ។ ខិតខំធ្វើពិពិធកម្មមូលដ្ឋានកំណើនសេដ្ឋកិច្ច ដោយឈរលើមូលដ្ឋានភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចកម្ពុជា និងការផ្សារភ្ជាប់សេដ្ឋកិច្ចកម្ពុជាជាមួយបណ្តាញផលិតកម្មក្នុងតំបន់ ក្នុងនោះយកចិត្តទុកដាក់ជាពិសេស ការបន្តអនុវត្តគោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ ដែលត្រូវបានចាត់ទុកជាមាស ស របស់កម្ពុជា ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្មន្តសាល និងកសិ-ឧស្សាហកម្ម ព្រមទាំងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យទេសចរណ៍ឆ្នាំ ២០១២-២០២០។

**១៧.** បន្តជំរុញការអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីសម្រេចបាននូវប្រព័ន្ធហិរញ្ញវត្ថុសាធារណៈមួយ ដែលមានលក្ខណៈស្តង់ដារអន្តរជាតិ សំដៅធ្វើឱ្យប្រព័ន្ធនេះក្លាយជាឧបករណ៍អភិវឌ្ឍន៍មួយដ៏មានប្រសិទ្ធភាពក្នុងការជំរុញកំណើនសេដ្ឋកិច្ច ធានាសមធម៌ យុត្តិធម៌សង្គម ធានាទ្រទ្រង់ប្រតិបត្តិការរបស់រដ្ឋ និងការផ្តល់សេវាសាធារណៈ ព្រមទាំងរួមចំណែករក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងស្ថិរភាពហិរញ្ញវត្ថុ។

ក្នុងគោលដៅខាងលើ ខាងផ្នែកចំណូល គឺខិតខំជំរុញការប្រមូលចំណូលថវិកាជាតិទាំងចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធឱ្យមានកំណើនជារៀងរាល់ឆ្នាំ។ ខាងផ្នែកចំណាយ គឺបន្តផ្តល់អាទិភាពលើវិស័យសេដ្ឋកិច្ច សង្គមកិច្ច ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការបង្កើនសមត្ថភាព និងការលើកកម្ពស់ជីវភាពរបស់មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ ។ ផ្សារភ្ជាប់ចំណាយសម្រាប់វិស័យនីមួយៗទៅនឹងគណនេយ្យភាពនៃសមិទ្ធកម្មនៅក្នុងវិស័យនោះ ។ ខិតខំបង្កើនអតិរេកចរន្ត ដើម្បីធានាដល់តម្រូវការវិនិយោគសាធារណៈ និងសេវាបំណុល ព្រមទាំងបង្កលក្ខណៈដល់ការសន្សំទុនបម្រុងរបស់រដ្ឋ ។ ក្នុងការគ្រប់គ្រងការប្រមូល

ចំណូល និងការចាត់ចែងចំណាយ ត្រូវផ្តោតលើប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ជាមួយគ្នានេះ បន្តយកចិត្តទុកដាក់ខ្ពស់ជានិច្ចក្នុងការគ្រប់គ្រងបំណុលសាធារណៈឱ្យស្ថិតក្នុងលទ្ធភាពទ្រទ្រង់នៃសេដ្ឋកិច្ចជាតិ។

**១៨.** បន្តអភិវឌ្ឍវិស័យហិរញ្ញវត្ថុ សំដៅកសាងប្រព័ន្ធហិរញ្ញវត្ថុមួយដ៏រឹងមាំ និងផ្អែកលើគោលការណ៍ទីផ្សារ ដែលបម្រើឱ្យការកៀរគរ និងបែងចែកធនធានប្រកបដោយប្រសិទ្ធភាព។ ប្រព័ន្ធនេះត្រូវមានការគ្រប់គ្រង ត្រួតពិនិត្យសមស្រប មានលក្ខណៈប្រកួតប្រជែង សមាហរណកម្ម តម្លាភាព និងប្រសិទ្ធភាព។ ក្នុងគោលដៅនេះ គណបក្សបន្តជំរុញការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០១១-២០២០ ដោយផ្តោតសំខាន់លើវិស័យធនាគារ និងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ សំដៅគាំទ្រដល់ពិពិធកម្មសេដ្ឋកិច្ចនវានុវត្តន៍ និងភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចកម្ពុជា ជាពិសេសវិស័យកសិ ឧស្សាហកម្ម និងកម្មន្តសាល ក៏ដូចលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុសម្រាប់សហគ្រាសធុនតូច មធ្យម និងសម្រាប់ប្រជាពលរដ្ឋទូទៅ ព្រមទាំងជំរុញការធ្វើសមាហរណកម្មហិរញ្ញវត្ថុជាមួយបណ្តាប្រទេសក្នុងអាស៊ាន។

**១៩.** អនុវត្តគោលនយោបាយរូបិយវត្ថុប្រកបដោយភាពទន់ភ្លន់ និងប្រុងប្រយ័ត្ន ដែលរួមចំណែកដល់ការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងបង្កើតបរិស្ថានអំណោយផលដល់ការអភិវឌ្ឍ។ បន្តរក្សារបបអត្រាប្តូរប្រាក់អណ្តែតមានការគ្រប់គ្រង ដើម្បីរក្សាស្ថិរភាពប្រាក់រៀល ពង្រឹងជំនឿទុកចិត្តរបស់សាធារណជន និងវិនិយោគិនមកលើប្រាក់រៀល ជំរុញការប្រើប្រាស់ប្រាក់រៀលលើមូលដ្ឋានស្ថិរភាពតម្លៃប្រាក់រៀល និងកាត់បន្ថយដុល្លារូបនីយកម្ម។ ពង្រឹងប្រព័ន្ធធនាគារឱ្យកាន់តែមានប្រសិទ្ធភាព សមាហរណកម្ម និងការប្រកួតប្រជែង តាមរយៈការបង្កើនប្រសិទ្ធភាពនៃការត្រួតពិនិត្យ ការគ្រប់គ្រងហានិភ័យសន្ទនីយភាព ហានិភ័យឥណទាន និងហានិភ័យទីផ្សារ ដោយអនុលោមតាមស្តង់ដារអន្តរជាតិ។ បន្តពង្រឹងប្រព័ន្ធមីក្រូហិរញ្ញវត្ថុឱ្យកាន់តែមានភាពរឹងមាំ មានប្រសិទ្ធភាព និងបម្រើផលប្រយោជន៍នៃស្រទាប់ប្រជាជនក្រីក្រ ជាមួយនឹងតម្លៃសេវាហិរញ្ញវត្ថុសមស្របដែលអាចទទួលយកបាន។ ព្រមជាមួយនេះ បន្តជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ដូចជា វិស័យធានារ៉ាប់រង វិស័យសោធន វិស័យមូលបត្រ និងវិស័យអចលនទ្រព្យ ជាដើម។

### ភាពជាដៃគូក្នុងការអភិវឌ្ឍ

**២០.** ពង្រឹងភាពជាដៃគូជាមួយសហគមន៍ដៃគូសហប្រតិបត្តិការអភិវឌ្ឍន៍ វិស័យឯកជន និងសង្គមស៊ីវិល ដោយឈរលើគោលការណ៍ជាមូលដ្ឋានដែលមានចរិតសកល និងធានាភាពជាម្ចាស់របស់រដ្ឋក្នុងការដឹកនាំការអភិវឌ្ឍប្រទេសជាតិ។ ពង្រឹងពង្រីកសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាល និងសមាគមនានា ដែលត្រូវបានបង្កើតឡើងដោយស្របច្បាប់ ហើយធ្វើប្រតិបត្តិការដោយឈរលើគោលការណ៍អភិបាលកិច្ចល្អ និងនីតិរដ្ឋ ដើម្បីចូលរួមក្នុងដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម ការលើកកម្ពស់លទ្ធិ-

ប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ព្រមទាំងចូលរួមតាមដានការអនុវត្តគោលនយោបាយផងដែរ។ បន្តពង្រឹងយន្តការវេទិកានៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា វេទិការាជរដ្ឋាភិបាលនិងវិស័យឯកជន និងវេទិការាជរដ្ឋាភិបាលជាមួយអង្គការមិនមែនរដ្ឋាភិបាល ហើយជំរុញឱ្យវេទិកាទាំងនេះក្លាយជាវេទិកាអភិវឌ្ឍន៍កម្ពុជា ដែលជាយន្តការសម្រាប់ឱ្យរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ទាំងអស់ចូលរួមពិភាក្សារាល់បញ្ហាដែលពាក់ព័ន្ធនឹងការអភិវឌ្ឍ ទាំងវិស័យសាធារណៈ ទាំងវិស័យឯកជន។

**កសិកម្ម**

**២១.** បន្តអភិវឌ្ឍវិស័យកសិកម្មឱ្យក្លាយជាផ្នែកនាំមុខមួយដែលមានប្រៀបខ្លាំងពិតប្រាកដ ដើម្បីធ្វើជាមូលដ្ឋានមួយដ៏រឹងមាំនៃកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ធានាសន្តិសុខស្បៀង បង្កើនការងារ និងប្រាក់ចំណូលសម្រាប់ប្រជាជន ជាពិសេសប្រជាជននៅជនបទ ហើយរួមចំណែកដល់ការការពារបរិស្ថាន និងធនធានធម្មជាតិប្រកបដោយនិរន្តរភាព។ ដើម្បីសម្រេចគោលដៅនេះ គណបក្សនឹងផ្តោតលើការអនុវត្តបណ្តាកម្មវិធីសំខាន់ៗ រួមមាន ការបញ្ចូលបច្ចេកវិទ្យាក្នុងវិស័យកសិកម្ម ការបង្កើនផលិតភាព និងពិពិធកម្មកសិកម្មទាំងការដាំដុះ និងការចិញ្ចឹម ការជំរុញការចូលទីផ្សារអន្តរជាតិនៃផលិតផលកសិកម្មរបស់កម្ពុជា ការគ្រប់គ្រង និងអភិវឌ្ឍធនធានជលផល និងការការពារ និងគ្រប់គ្រងធនធានព្រៃឈើប្រកបដោយចីរភាព ។

**២២.** ខិតខំសម្រេចគោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករឱ្យបាន ១លានតោន នៅឆ្នាំ ២០១៥ សំដៅប្រែក្លាយកម្ពុជាទៅជាប្រទេសផលិតស្បៀងនាំមុខមួយនៅលើពិភពលោក ។ រក្សាផ្ទៃនេសាទទឹកសាបសម្រាប់ប្រជាជនធ្វើនេសាទជាលក្ខណៈគ្រួសារ ពង្រីងតំបន់អភិរក្ស បង្កើនការការពារធនធានជលផល លុបបំបាត់បទល្មើសនេសាទគ្រប់រូបភាព និងជំរុញការអភិវឌ្ឍវារីវប្បកម្ម រួមនឹងការបន្តពង្រឹង និងពង្រីកសហគមន៍នេសាទ។ រក្សាផ្ទៃដីដែលគ្របដណ្តប់ដោយព្រៃឈើ ដោយត្រូវបង្កើនការការពារធនធានព្រៃឈើ ពិសេសការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ ការទប់ស្កាត់បង្ក្រាបបទល្មើសព្រៃឈើ ជំរុញការដាំដើមឈើឡើងវិញ និងបង្កើនសមត្ថភាពសហគមន៍ព្រៃឈើ លើមូលដ្ឋានធានានិរន្តរភាព និងប្រសិទ្ធភាពគ្រប់គ្រង។

**២៣.** ជំរុញការអភិវឌ្ឍដំណាំកៅស៊ូឱ្យរីកចម្រើនទាំងបរិមាណ និងគុណភាព ក្លាយជាវិស័យដ៏មានសក្តានុពល និងភាពប្រកួតប្រជែង តាមរយៈការពង្រីកការដាំដុះកៅស៊ូប្រកបដោយទិន្នផលខ្ពស់ ដោយបន្តអនុវត្តយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍកៅស៊ូធម្មជាតិនៅកម្ពុជា ឆ្នាំ ២០១១-២០២០ សំដៅធ្វើឱ្យផ្ទៃដីដាំកៅស៊ូកើនឡើងដល់ជាង ៣០០ ០០០ ហ.ត និងមានបរិមាណផលិតផលពី ២៥០ ០០០ ទៅ ៣០០ ០០០តោន នៅឆ្នាំ ២០២០។ យុទ្ធសាស្ត្រអភិវឌ្ឍន៍កៅស៊ូធម្មជាតិនឹងផ្តោតលើការធានាគុណភាព និងផលិតភាពនៃការដាំដុះកៅស៊ូ ការសិក្សាលទ្ធភាពប្រើប្រាស់សក្តានុភាពដីទំនេរដែលអាចដាំកៅស៊ូបាន

ការជំរុញការដាំដុះកៅស៊ូគ្រួសារ ការជំរុញចម្ការកៅស៊ូឧស្សាហកម្ម ធ្វើជាស្នូលនៃការអភិវឌ្ឍចម្ការកៅស៊ូគ្រួសារ និងការជំរុញតម្លៃឱ្យបានខ្ពស់។

**២៤.** ផ្អាកការផ្តល់សម្បទានដីសេដ្ឋកិច្ច ឬជួលអចិន្ត្រៃយ៍។ ធ្វើសន្និធិដីសម្បទានសេដ្ឋកិច្ច ហើយពង្រឹងការគ្រប់គ្រងប្រភេទដីនេះឱ្យបានត្រឹមត្រូវតាមច្បាប់ លិខិតបទដ្ឋាន និងកិច្ចសន្យា ជាពិសេសតាមរយៈការបង្កើនយន្តការចុះពិនិត្យផ្ទៀងផ្ទាត់ជាប្រចាំនូវសកម្មភាពវិនិយោគរបស់ក្រុមហ៊ុនដែលទទួលដីសម្បទាននានាដែលបានចុះកិច្ចសន្យាជាមួយរាជរដ្ឋាភិបាល ដើម្បីធានាដល់កិច្ចដំណើរការនៃសកម្មភាពវិនិយោគផង និងការទប់ស្កាត់នូវភាពអសកម្មផ្សេងៗ ដែលអាចកើតមានទាក់ទងនឹងដីសម្បទានផង។

## ដីធ្លី និងសំណង់

**២៥.** បន្តអនុវត្តការកែទម្រង់ដីធ្លី ដែលផ្តោតលើការងាររដ្ឋបាលដីធ្លី ការងាររៀបចំដែនដី និងនគរូបនីយកម្ម ការងារបែងចែកដីធ្លី និងការអភិវឌ្ឍវិស័យសំណង់ ដើម្បីធានាការការពារសិទ្ធិលើដីធ្លីរបស់ប្រជាជន ព្រមទាំងការគ្រប់គ្រងការប្រើប្រាស់ធនធានធម្មជាតិ និងដីរដ្ឋ ប្រកបដោយតម្លាភាព សមធម៌ ចីរភាព និងប្រសិទ្ធភាព។ បន្តអនុវត្តនយោបាយមិនយកពន្ធលើដីធ្លីកសិកម្មរបស់កសិករ ដែលបង្កបង្កើនផលជាលក្ខណៈគ្រួសារ ។

**២៦.** លើផ្នែករដ្ឋបាលដីធ្លី បន្តជំរុញការចុះបញ្ជីដី និងផ្តល់កម្មសិទ្ធិដី ទាំងដីរដ្ឋ ដីឯកជន និងដីសហគមន៍ ដើម្បីធានាសុវត្ថិភាពនៃការកាន់កាប់ដីធ្លី ដោយជំរុញល្បឿននៃការចុះបញ្ជីដី សំដៅឈានទៅសម្រេចឱ្យបាន ១០០% នូវការចុះបញ្ជីដីតាមផែនការនៃបទបញ្ជាលេខ ០១ របស់រាជរដ្ឋាភិបាល **ជិត ២លានហ.ត.** នៅរវាងដើមឆ្នាំ ២០១៤ ក្នុងក្របខ័ណ្ឌនៃការអនុវត្ត "នយោបាយចាស់ សកម្មភាពថ្មីលើវិស័យដីធ្លី" និងសម្រេចឱ្យបាន ៧០% ដល់ឆ្នាំ២០១៨ លើបរិមាណក្បាលដីដែលត្រូវចុះបញ្ជីសរុប ៦ ទៅ ៧លានក្បាលដីក្នុងទូទាំងប្រទេស។ ខិតខំកាត់បន្ថយ និងឈានទៅលុបបំបាត់ឱ្យបានភាពអនាធិបតេយ្យរំលោភកាន់កាប់ដីគ្រប់ប្រភេទដោយខុសច្បាប់ ទប់ស្កាត់ការប្រមូលដីទុកមិនប្រើប្រាស់ ឬមិនធ្វើអាជីវកម្ម ដោះស្រាយទំនាស់ដីធ្លីប្រកបដោយតម្លាភាព និងយុត្តិធម៌ ដោយពង្រឹងការប្រតិបត្តិឱ្យបានត្រឹមត្រូវតាមក្របខ័ណ្ឌគតិយុត្តិជាធរមាន ព្រមទាំងឆ្លើយតបទៅនឹងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៃការងារដីធ្លី ។ ជំរុញការកំណត់ព្រំប្រទល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការកសាងយុទ្ធសាស្ត្រជាតិនៃការអភិវឌ្ឍទីក្រុង ទីប្រជុំជន និងតំបន់ឆ្នេរ។

**២៧.** លើផ្នែករៀបចំដែនដី គឺធានាការគ្រប់គ្រង ការការពារ និងការប្រើប្រាស់ដី និងធនធានធម្មជាតិ ប្រកបដោយតម្លាភាព និងប្រសិទ្ធភាព ដើម្បីរក្សានិរន្តរភាពបរិស្ថាន និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ប្រកបដោយសមធម៌ទាំងនៅទីប្រជុំជន និងជនបទ ព្រមទាំងទប់ស្កាត់វិវាទនៃការប្រើប្រាស់ដី ដោយ

ពង្រឹងការអនុវត្តតាមច្បាប់ស្ដីពីការរៀបចំដែនដី និងនគរូបនីយកម្ម ច្បាប់សំណង់ ក្របខណ្ឌយុទ្ធសាស្ត្រនៃគោលនយោបាយដីធ្លី គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងអភិបាលកិច្ចល្អ។ ទន្ទឹមនេះកសាងគោលនយោបាយជាតិស្ដីពីលំនៅស្ថាន ដើម្បីដោះស្រាយលំនៅស្ថានជូនប្រជាពលរដ្ឋក្រីក្រសម្រាប់ការរស់នៅប្រកបដោយសុវត្ថិភាព សុខុមាលភាព និងភាពថ្លៃថ្នូរ។

**២៨.** លើផ្នែកបែងចែកដី គឺផ្ដល់ទិសដៅច្បាស់លាស់ដើម្បីធ្វើការបែងចែក និងប្រើប្រាស់ដីរដ្ឋសម្រាប់គោលបំណងឯកជន និងសាធារណៈប្រកបដោយតម្លាភាព និងសមធម៌ ឆ្លើយតបទៅនឹងតម្រូវការដីរបស់ប្រជាពលរដ្ឋទូទៅ ជាពិសេសប្រជាពលរដ្ឋក្រីក្រ យុទ្ធជនពិការ គ្រួសារយុទ្ធជនពលី អតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារដែលគ្មានដី ខ្វះដី ហើយត្រូវការដីពិតប្រាកដ តាមរយៈកម្មវិធីសម្បទានដីសង្គមកិច្ច និងការធ្វើប្រទានកម្ម ដោយធានាឱ្យបាននូវសមធម៌ ស្ថិរភាពសង្គម សន្តិសុខស្បៀង និងការសម្រួលដល់ការវិនិយោគ។ បង្កើនល្បឿនផ្ដល់សម្បទានដីសង្គមកិច្ច លើមូលដ្ឋាននៃសន្និធិដីរដ្ឋក្នុងការអនុវត្តនយោបាយចាស់ សកម្មភាពថ្មីលើវិស័យដីធ្លី សម្រាប់គោលដៅនេះ។ ទប់ស្កាត់ការកើតមានទៀតនូវភាពមិនប្រក្រតីនៃការទន្ទ្រានកាន់កាប់ដីរដ្ឋ។

បន្តជំរុញសកម្មភាព បោសសម្អាតមីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះ និងអនុវត្តការបែងចែកដីដែលបានបោសសម្អាតរួចជូនប្រជាជនដែលខ្វះដីប្រកបដោយសមធម៌។

**២៩.** ពង្រឹងការគ្រប់គ្រង និងអភិវឌ្ឍវិស័យសំណង់ ដែលជាសសរស្ដម្ភមួយនៃកំណើនសេដ្ឋកិច្ចកំពុងមានការរីកចម្រើនយ៉ាងខ្លាំង ដោយផ្ដោតលើការជំរុញវិនិយោគក្នុងវិស័យសំណង់ ការកសាងច្បាប់ការកំណត់ស្ដង់ដារសំណង់ និងការពន្លឿនរយៈពេលចេញលិខិតអនុញ្ញាតសាងសង់ជូនប្រជាជន។

## ឧស្សាហកម្ម សិប្បកម្ម ធនធានរ៉ែ

**៣០.** អភិវឌ្ឍវិស័យឧស្សាហកម្មកម្មន្តសាល សិប្បកម្ម ប្រកបដោយនិរន្តរភាព ដែលមានលក្ខណៈចម្រុះសម្បូរបែប មានការទទួលខុសត្រូវខាងបរិស្ថាន និងសង្គមខ្ពស់ ហើយពង្រីកបាននូវអន្តរកម្មសេដ្ឋកិច្ចរវាងផ្នែកកែច្នៃកម្មន្តសាល ជាមួយវិស័យកសិកម្ម ពាណិជ្ជកម្ម និងសេវាកម្ម ដើម្បីជំរុញសមាហរណកម្មសេដ្ឋកិច្ច ខ្សែចង្វាក់តម្លៃ និងភាពប្រកួតប្រជែងរបស់កម្ពុជានៅក្នុងតំបន់ និងពិភពលោក។ ឆ្លងតាមការជំរុញអភិវឌ្ឍវិស័យឧស្សាហកម្ម យើងនឹងអនុវត្តបានជាជំហានៗនូវការពង្រឹងប្រព័ន្ធសហគ្រាសធុនតូច និងមធ្យម និងការធ្វើទំនើបភាវូបនីយកម្មសេដ្ឋកិច្ច ដែលនឹងនាំកម្ពុជាឈានទៅដល់ដំណាក់កាលថ្មីនៃពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ច តាមរយៈការប្រើប្រាស់បណ្ដាលក្ខខណ្ឌអំណោយផល និងឧត្ដមភាពប្រៀបធៀបរបស់កម្ពុជាប្រកបដោយប្រសិទ្ធភាព ។

**៣១.** ក្នុងដំណើរការអភិវឌ្ឍន៍វិស័យនេះ គណបក្សផ្តោតការប្រឹងប្រែងថែមទៀតលើការពង្រឹងភាពអំណោយផលនៃបរិស្ថានវិនិយោគ ការជំរុញការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស ការលើកកម្ពស់ផលិតភាព និងសហគ្រិនភាពរបស់សហគ្រាសធុនតូច និងមធ្យម ការពង្រីកលទ្ធភាពទទួលបានបច្ចេកវិទ្យាជឿនលឿន ការបណ្តុះបណ្តាលជំនាញ និងវិជ្ជាជីវៈ ព្រមទាំងការលើកកម្ពស់ការងារស្តង់ដារូបនីយកម្ម ការវាយតម្លៃភាពអនុលោម និងមាត្រាសាស្ត្រ ។ ទិសដៅជាសារវន្តនៃគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មនៅពេលខាងមុខនេះ គឺការច្បាមយកតម្លៃបន្ថែមឱ្យបានកាន់តែច្រើននៅក្នុងវិស័យសំខាន់ៗដែលមានស្រាប់ រួមមានវិស័យកសិកម្ម ឧស្សាហកម្មកាត់ដេរ និងទេសចរណ៍ ការលើកស្ទួយប្រភេទឧស្សាហកម្មថ្មីៗដែលមានសក្តានុពលរីកលូតលាស់ និងការខិតខំបង្កើតឧត្តមភាពប្រៀបធៀបថ្មីទៀត ក្នុងវិស័យឧស្សាហកម្ម។

**៣២.** អភិវឌ្ឍធនធានរ៉ែ ប្រេងកាត និងឧស្ម័ន ដើម្បីប្រែក្លាយធនធាននេះឱ្យទៅជាប្រភពថ្មីមួយទៀតនៃកំណើនសេដ្ឋកិច្ចរបស់កម្ពុជា។ លើកទឹកចិត្តឱ្យវិស័យឯកជនវិនិយោគលើការសិក្សាស្រាវជ្រាវ និងការធ្វើអាជីវកម្មធនធានទាំងនោះ តាមច្បាប់ជាធរមាន ដោយយកចិត្តទុកដាក់ជាសំខាន់ទៅលើសុវត្ថិភាព សុខុមាលភាព ព្រមទាំងការការពារបរិស្ថាន និងសង្គម។ បន្តរៀបចំ និងធ្វើបច្ចុប្បន្នភាព បទប្បញ្ញត្តិ និងលិខិតបទដ្ឋាននានា ដែលទាក់ទងនឹងធនធានរ៉ែ ប្រេងកាត និងឧស្ម័ន ដើម្បីធានាការអភិវឌ្ឍធនធាននេះប្រកបដោយប្រសិទ្ធភាព និងមានការទទួលខុសត្រូវខ្ពស់។ ចំណូលដែលបានមកពីធនធានរ៉ែ ប្រេងកាត និងឧស្ម័នត្រូវបានគ្រប់គ្រង និងប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ដោយផ្សារភ្ជាប់ជាមួយកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

### ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

### ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍

**៣៣.** នៅក្នុងដំណាក់កាលដែលសេដ្ឋកិច្ចកម្ពុជាកំពុងតែស្ថិតក្នុងស្ថានភាពហក់ឡើង ឈានទៅរកដំណាក់កាលរីកចម្រើនមួយថ្មីទៀតខ្ពស់ជាង បណ្តាញគមនាគមន៍និងដឹកជញ្ជូនកាន់តែមានតួនាទីដ៏សំខាន់ជាក្បាលរថភ្លើងនៃកំណើនសេដ្ឋកិច្ច និងជាសរសៃឈាមសម្រាប់ចិញ្ចឹមសេដ្ឋកិច្ចជាតិ ប្រព័ន្ធសហគ្រាសធុនតូច និងមធ្យម និងសេដ្ឋកិច្ចគ្រួសារ។ គណបក្សនឹងបន្តបង្កើនការស្តារ សាងសង់ និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនប្រកបដោយគុណភាពសម្រាប់បម្រើឱ្យការដឹកជញ្ជូនពហុរូបភាព គឺ ទាំងការដឹកជញ្ជូនផ្លូវគោក ផ្លូវដែក ផ្លូវទឹក កំពង់ផែ និងការដឹកជញ្ជូនផ្លូវអាកាស ដែលតភ្ជាប់រវាងគ្រប់តំបន់នៅទូទាំងប្រទេស តភ្ជាប់ជាមួយបណ្តាប្រទេសក្នុងតំបន់ និងពិភពលោក ដើម្បីធានាការធ្វើដំណើរទៅគ្រប់ច្រកល្ហក និងការផ្តល់សេវាដឹកជញ្ជូនបានគ្រប់គ្រាន់ គ្រប់រដូវកាលប្រកបដោយផាសុកភាព សណ្តាប់ធ្នាប់ ប្រសិទ្ធភាព និងមានតម្លៃ

ទាប ។ ផ្អែកលើមូលដ្ឋាននេះនឹងកាន់តែបង្កលក្ខណៈដល់សមាហរណកម្មផ្ទៃក្នុងរបស់កម្ពុជា សមាហរណកម្មនៅក្នុងតំបន់ និងពិភពលោក ជំរុញការអភិវឌ្ឍគ្រប់វិស័យសេដ្ឋកិច្ច សម្រួលការធ្វើពាណិជ្ជកម្ម ទេសចរណ៍ ព្រមទាំងបម្រើដល់កិច្ចការពារជាតិបានកាន់តែល្អប្រសើរ ។

**៣៤.** បន្តផ្តល់អាទិភាពខ្ពស់ដល់ការស្តារ និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់គ្រប់ប្រភេទ ទាំងផ្លូវជាតិ ផ្លូវខេត្ត និងផ្លូវជនបទ ក្នុងនោះ ខិតខំកែលម្អផ្លូវលំជនបទជាជំហានៗ ពីផ្លូវក្រាលក្រួសក្រហមទៅជាផ្លូវក្រាលកៅស៊ូ ឬផ្លូវបេតុង ឱ្យបានពី ៣០០ ទៅ ៤០០ គ.ម ក្នុង១ឆ្នាំ តាមស្តង់ដារឯកភាពជាតិមួយ ។ ការស្តារ និងអភិវឌ្ឍផ្លូវត្រូវដើរទន្ទឹមនឹងការពង្រឹងរាល់វិធានការដ៏ម៉ឺងម៉ាត់ ដើម្បីធានាការគ្រប់គ្រងការងារថែទាំផ្លូវថ្នល់ឱ្យមាននិរន្តរភាព ។ លើកទឹកចិត្តជំរុញការចូលរួមពីផ្នែកឯកជនក្នុងការវិនិយោគលើការអភិវឌ្ឍ និងថែទាំហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំងសេវាកម្មដឹកជញ្ជូន ។ លើកកម្ពស់ប្រសិទ្ធភាពគ្រប់គ្រងមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទឱ្យមានលក្ខណសម្បត្តិខាងបច្ចេកទេសគ្រប់គ្រាន់ដើម្បីធ្វើចរាចរណ៍លើផ្លូវសាធារណៈ ។ ទន្ទឹមនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ត្រូវបង្កើនការផ្សព្វផ្សាយអប់រំដល់ប្រជាជនទូទៅឱ្យបានយល់ដឹងច្បាស់អំពីច្បាប់ចរាចរណ៍ ហើយចូលរួមអនុវត្តយ៉ាងសកម្ម ដើម្បីធានាសុវត្ថិភាពចរាចរណ៍ និងការគោរពថែរក្សាទ្រព្យសម្បត្តិសាធារណៈ ។

រៀបចំគោលនយោបាយដឹកជញ្ជូនក្នុងទីក្រុង ជាពិសេសរាជធានីភ្នំពេញសម្រាប់រយៈពេលមធ្យម និងរយៈពេលវែង ដើម្បីពង្រីកហេដ្ឋារចនាសម្ព័ន្ធ កសាងមធ្យោបាយដឹកជញ្ជូនរួមប្រយោជន៍នឹងដោះស្រាយបញ្ហាកកស្ទះ និងពង្រឹងសណ្តាប់ធ្នាប់ចរាចរណ៍ក្នុងទីក្រុង ដែលកាន់តែមានភាពលំបាកស្មុគស្មាញឡើងពីមួយថ្ងៃទៅមួយថ្ងៃ អាស្រ័យដោយកំណើនប្រជាជន និងកំណើនយ៉ាងលឿននៃបរិមាណយានយន្តគ្រប់ប្រភេទ ។

**៣៥.** បន្តស្តារឡើងវិញបណ្តាញផ្លូវដែកនៅកម្ពុជាដែលមានស្រាប់គឺ បណ្តាញពាយ័ព្យទិស និងនិរតីទិស ដើម្បីពង្រីកវិសាលភាពនៃការដឹកជញ្ជូនទំនិញ អ្នកដំណើរ និងការដឹកជញ្ជូនឆ្លងកាត់ព្រំដែន ព្រមទាំងធ្វើសមាហរណកម្មផ្លូវដែកកម្ពុជាទៅក្នុងប្រព័ន្ធផ្លូវដែកតំបន់អាស៊ាន និងមហាអនុតំបន់មេគង្គ ។

**៣៦.** ពង្រឹងយន្តការគ្រប់គ្រង និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនផ្លូវសមុទ្រ និងដឹកជញ្ជូនផ្លូវទន្លេ ដើម្បីរៀបចំប្រព័ន្ធដឹកជញ្ជូនទាំងពីរ ជាលក្ខណៈតំបន់ និងអន្តរជាតិប្រកបដោយប្រសិទ្ធភាព មានការប្រកួតប្រជែងដោយស្មើភាព ធានាបរិស្ថានទន្លេ សមុទ្របានល្អ ព្រមទាំងធ្វើឱ្យកាន់តែប្រសើរនូវតួនាទីរបស់កំពង់ផែ ក្នុងការសម្រួលពាណិជ្ជកម្ម ចរាចរណ៍ទំនិញ និងទេសចរណ៍ ។

**៣៧.** បន្តស្តារ និងអភិវឌ្ឍអាកាសយានដ្ឋានជាតិ-អន្តរជាតិ និងប្រព័ន្ធនាំផ្លូវអាកាសនៃព្រះរាជាណាចក្រកម្ពុជា លើកកម្ពស់ការពង្រឹងសុវត្ថិភាព សន្តិសុខអាកាសចរណ៍ និងការការពារបរិស្ថាន ដើម្បី

បង្កើនផលប្រយោជន៍ខាងសេដ្ឋកិច្ច ជំរុញវិស័យពាណិជ្ជកម្ម ទេសចរណ៍ និងធ្វើឱ្យមានសង្គតិភាពជាមួយគោលនយោបាយដឹកជញ្ជូនផ្លូវអាកាសថ្នាក់តំបន់ អនុតំបន់ និងអន្តរជាតិ ។

**ធនធានទឹក**

**៣៨.** លើកកម្ពស់ការគ្រប់គ្រង ថែរក្សា និងប្រើប្រាស់ធនធានទឹកប្រកបដោយប្រសិទ្ធភាព មាននិរន្តរភាព និងរក្សាបាននូវប្រព័ន្ធអេកូឡូស៊ី ដើម្បីផ្តល់លទ្ធភាពដល់ជនគ្រប់រូបក្នុងការប្រើប្រាស់ទឹកដែលមានអនាម័យ សុវត្ថិភាព និងតម្លៃសមស្រប សម្រាប់ផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃបានគ្រប់គ្រាន់ ធានាការគ្រប់គ្រងនិងបែងចែកទឹកឱ្យមានសមភាពសម្រាប់ការអភិវឌ្ឍវិស័យកសិកម្ម ឧស្សាហកម្ម សេវាកម្ម និងសកម្មភាពសេដ្ឋកិច្ចផ្សេងៗទៀត ធានាការគ្រប់គ្រងបរិមាណ និងគុណភាពទឹក ទាំងទឹកលើដី ទាំងទឹកក្រោមដី ហើយកាត់បន្ថយឱ្យបានជាអតិបរមានូវគ្រោះគំរាមកំហែងដល់អាយុជីវិត និងការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋពីគ្រោះមហន្តរាយដែលបង្កឡើងដោយទឹក ។ ពង្រឹងការគ្រប់គ្រងធនធានទឹក ដោយជំរុញឱ្យមានការគោរពកិច្ចព្រមព្រៀងអន្តរប្រទេសលើការគ្រប់គ្រងទឹកដងទន្លេមេគង្គ និងចាត់ទុកទឹកជាទ្រព្យសម្បត្តិសាធារណៈដែលត្រូវគោរព និងការពារ ។

**៣៩.** បន្តផ្តល់អាទិភាពលើការស្តារ កសាង ថែទាំ និងគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធស្រោចស្រពដែលត្រូវតែមានប្រសិទ្ធភាពសេដ្ឋកិច្ច ហើយត្រូវតែធានាបាននូវផលនៃការវិនិយោគ ក្នុងនោះរួមមាន អាងស្តុកទឹក ប្រឡាយទឹក សំណង់ទ្វារទឹក លូទឹក ប្រឡាយនាំដីល្បាប់ ប្រព័ន្ធដោះទឹក ទំនប់ការពារទឹកជំនន់ ការពារទឹកប្រៃ និងស្ថានីយបូមទឹក ដើម្បីបង្កើនផ្ទៃដីស្រោចស្រពជាមធ្យម ២៥០០០ ហ.ត ក្នុង ១ឆ្នាំ ជំរុញការបង្កបង្កើនផល ពង្រីកវារីវប្បកម្ម កាត់បន្ថយមហន្តរាយដែលបណ្តាលមកពីគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត ព្រមទាំងសម្រួលដល់ការធ្វើដំណើររបស់ប្រជាជន។ ជំរុញការផលិតឧបករណ៍ និងមធ្យោបាយបម្រើឱ្យវិស័យធនធានទឹក។

**៤០.** ពង្រឹងការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងបទប្បញ្ញត្តិពាក់ព័ន្ធនានា ដើម្បីទប់ស្កាត់រាល់សកម្មភាព ឬគម្រោងសាងសង់នានាដែលអាចធ្វើឱ្យប៉ះពាល់មកលើធនធានទឹកក៏ដូចជាប្រព័ន្ធអេកូឡូស៊ី ។ រាំងស្កាត់ និងមានវិធានការម៉ឺងម៉ាត់ចំពោះសកម្មភាពចាក់លុបបំពេញដី ការជីកថ្មី ឬការរំលោភលើផ្លូវទឹកទន្លេ ស្ទឹង បឹងបួរ ព្រែក ឬតំបន់ទំនាបសមុទ្រ និងទីលិចទឹកជាប្រចាំ ដែលគ្មានច្បាប់អនុញ្ញាត ហើយអាចធ្វើឱ្យប៉ះពាល់មកលើធនធានទឹក ក៏ដូចប្រព័ន្ធអេកូឡូស៊ី និងបរិស្ថាន។

**៤១.** បន្តធ្វើសមាហរណកម្មកម្ពុជាជាមួយសហគមន៍អន្តរជាតិក្នុងវិស័យទឹក ដើម្បីជំរុញកិច្ចសហប្រតិបត្តិការ និងការយោគយល់ជាអន្តរជាតិក្នុងវិស័យនេះ។ សហការពេញទំហឹងជាមួយបណ្តាប្រទេសជិត

ខាងដែលមានព្រំប្រទល់ជាប់នឹងកម្ពុជា ព្រមទាំងជាមួយនឹងប្រទេសក្នុងតំបន់ ដើម្បីសម្រេចគោលបំណង នៃកិច្ចព្រមព្រៀងមេគង្គឆ្នាំ១៩៩៥ ស្តីពីកិច្ចសហប្រតិបត្តិការក្នុងការអភិវឌ្ឍអាងទន្លេមេគង្គប្រកបដោយនិរន្តរភាព។

**ទឹកស្អាត**

**៤២.** ជំរុញការអភិវឌ្ឍ និងវិចារណកម្មការគ្រប់គ្រងវិស័យផ្គត់ផ្គង់ទឹកស្អាតសម្រាប់ប្រើប្រាស់ក្នុងជីវភាពរស់នៅរបស់ប្រជាជន និងផលិតកម្ម សេវាកម្ម ប្រកបដោយគុណភាព ប្រសិទ្ធភាព និងថ្លៃសមរម្យ ដើម្បីរួមចំណែកលើកកម្ពស់សុខុមាលភាព ជាពិសេសកាត់បន្ថយកង្វះទឹកស្អាតប្រើប្រាស់សម្រាប់ប្រជាជនដែលរស់នៅក្នុងតំបន់ទីប្រជុំជន ជាយក្រុង និងជនបទ។ គោលដៅក្នុងការផ្គត់ផ្គង់ទឹកស្អាត គឺដល់ឆ្នាំ ២០១៨ ប្រជាជនចំនួន ៨៥% ដែលរស់នៅរាជធានី ខេត្ត និងប្រជាជនចំនួន ៦០% ដែលរស់នៅតាមបណ្តាឃុំ បានទទួលសេវាទឹកស្អាតដែលមានគុណភាពល្អ និងថ្លៃសមរម្យប្រើប្រាស់ តាមរយៈការពង្រីកសមត្ថភាពផលិត និងផ្គត់ផ្គង់ទឹកស្អាតនៅរាជធានី ខេត្ត និងពង្រីកការចូលរួមរបស់ផ្នែកឯកជនក្នុងការវិនិយោគលើវិស័យផ្គត់ផ្គង់ទឹកស្អាត ។

**ថាមពល**

**៤៣.** បន្តអភិវឌ្ឍវិស័យថាមពល ដើម្បីធានាការផ្គត់ផ្គង់ថាមពលដែលមានស្ថិរភាព ការជឿទុកចិត្ត និងថ្លៃសមរម្យ សម្រាប់បម្រើជីវភាពរស់នៅរបស់ប្រជាជន ការផ្តល់សេវានានាដល់សង្គម និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ដោយផ្តោតលើទិសដៅធំៗ ២ គឺ : បន្តសាងសង់ស្ថានីយផលិតអគ្គិសនីក្នុងស្រុក និងធ្វើសមាហរណកម្មប្រព័ន្ធថាមពលកម្ពុជាទៅក្នុងប្រព័ន្ធថាមពលរបស់តំបន់អាស៊ាន និងមហាអនុតំបន់មេគង្គ សំដៅបង្កើតប្រភពថាមពលឱ្យបានគ្រប់គ្រាន់ និងមានស្ថិរភាពសម្រាប់កម្ពុជា ទន្ទឹមនេះ បន្តអភិវឌ្ឍបណ្តាញបញ្ជូន អនុស្ថានីយ បណ្តាញបញ្ជូនរង និងបណ្តាញចែកចាយអគ្គិសនីឱ្យឆាប់បានគ្របដណ្តប់ទូទាំងប្រទេស ដើម្បីបញ្ជូនថាមពលដែលមានស្ថិរភាព និងថ្លៃសមរម្យទៅផ្គត់ផ្គង់ដល់លំនៅស្ថានប្រជាជន និងទីតាំងបម្រើសកម្មភាពសង្គម និងសេដ្ឋកិច្ច។

**៤៤.** ជំរុញការធ្វើពិពិធកម្មថាមពល ក្នុងនោះក៏រួមមានការបង្កើតប្រភពថាមពលស្អាត និងថាមពលកកើតឡើងវិញផងដែរ ពង្រឹងសន្តិសុខថាមពល ខិតខំកាត់បន្ថយឱ្យបានជាអតិបរមានូវផលប៉ះពាល់លើបរិស្ថានធម្មជាតិ និងសង្គមក្នុងដំណើរការផលិតថាមពល ។ បន្តអនុវត្តតួនាទីនាំមុខរបស់រដ្ឋក្នុងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់អគ្គិសនី ជាមួយគ្នានេះ គាំទ្រនិងលើកទឹកចិត្តដល់ការចូលរួមរបស់ផ្នែកឯកជនក្នុងការវិនិយោគ និងធ្វើអាជីវកម្មផ្តល់សេវាអគ្គិសនី ដែលគោរពតាមការកំណត់នៃច្បាប់ បទប្បញ្ញត្តិ ស្តង់ដារ

និងនីតិវិធីជាធរមាន ជាពិសេសការអនុវត្តថ្លៃលក់អគ្គិសនីឱ្យបានត្រឹមត្រូវតាមច្បាប់អគ្គិសនី ដើម្បីការពារផលប្រយោជន៍ និងភាពយុត្តិធម៌ទាំងសម្រាប់អ្នកផលិត អ្នកបញ្ជូន អ្នកចែកចាយ និងអ្នកប្រើប្រាស់។

នៅក្នុងដំណើរការអគ្គិសនីភាវូបនីយកម្មជនបទ គោលដៅនៃវិស័យថាមពលពីឆ្នាំ ២០១៣ ដល់ ២០១៨ គឺពង្រីកការផ្គត់ផ្គង់អគ្គិសនីពីបណ្តាញជាតិឱ្យដល់ភូមិចំនួន ៨០% នៃចំនួនភូមិទាំងអស់ និងដោះស្រាយការផ្គត់ផ្គង់អគ្គិសនីដោយវិធីផ្សេងៗទៀតឱ្យបាន ១០% នៃចំនួនភូមិទាំងអស់ លើគោលដៅ ១០០% នៃភូមិនៅឆ្នាំ ២០២០ ហើយរហូតដល់ឆ្នាំ ២០៣០ មាន ៧០%នៃគ្រួសារទាំងអស់នឹងមានអគ្គិសនីដែលមានគុណភាពដូចអគ្គិសនីពីបណ្តាញជាតិប្រើប្រាស់ ។ ខិតខំរកលទ្ធភាពជួយប្រជាជនក្រីក្រនៅតំបន់ជនបទឱ្យអាចប្រើប្រាស់អគ្គិសនីពីបណ្តាញផ្គត់ផ្គង់ ទាំងលទ្ធភាពភ្ជាប់ចរន្តពីបណ្តាញ ទាំងថ្លៃអគ្គិសនី ។

### បច្ចេកវិទ្យាព័ត៌មានគមនាគមន៍

**៤៥.** បច្ចេកវិទ្យាព័ត៌មានគមនាគមន៍ជានិមិត្តរូបនៃវឌ្ឍនភាពរបស់មនុស្សជាតិក្នុងសម័យកាលបច្ចុប្បន្ននេះ ដែលកម្ពុជាត្រូវតែចាប់យកឱ្យបាន និងដើរឱ្យទាន់ការរីកចម្រើនរបស់បណ្តាប្រទេសក្នុងតំបន់ ដើម្បីជំរុញការអភិវឌ្ឍប្រទេសលើគ្រប់វិស័យ ការលើកកម្ពស់ប្រសិទ្ធភាពនៃស្ថាប័នរដ្ឋក៏ដូចឯកជន និងការលើកស្ទួយជីវភាពរបស់ប្រជាជន។ បន្តអភិវឌ្ឍប្រព័ន្ធប្រៃសណីយ៍ និងទូរគមនាគមន៍ ព្រមទាំងបច្ចេកវិទ្យាព័ត៌មានគមនាគមន៍ឱ្យមានលក្ខណៈទំនើប មានគុណភាពខ្ពស់ស្របតាមស្តង់ដារអន្តរជាតិ មានថ្លៃសមរម្យ និងមានសេវាគ្របដណ្តប់នៅទូទាំងប្រទេស ដែលប្រជាជនទូទៅអាចប្រើប្រាស់ និងទទួលបានផលប្រយោជន៍គ្រប់ៗគ្នាពីសេវាកម្មនេះ។ លើកទឹកចិត្តវិនិយោគឯកជនធ្វើទំនើបកម្មបច្ចេកវិទ្យាព័ត៌មានគមនាគមន៍ ជំរុញការប្រកួតប្រជែងដោយយុត្តិធម៌ក្នុងទីផ្សារសេវាប្រៃសណីយ៍ និងទូរគមនាគមន៍ដោយផ្អែកលើច្បាប់ និងលិខិតបទដ្ឋាននានា។ ទប់ស្កាត់ការធ្វើអាជីវកម្មផ្តាច់មុខក្នុងវិស័យប្រៃសណីយ៍ និងវិស័យបច្ចេកវិទ្យាព័ត៌មានគមនាគមន៍ ដោយចាត់ទុកវិស័យទាំងពីរ ជាទំនិញ និងសេវាសាធារណៈផង និងជាទ្រព្យសម្បត្តិសាធារណៈផង ។

ពង្រីកការកសាងហេដ្ឋារចនាសម្ព័ន្ធឆ្អឹងខ្នង បណ្តាញខ្សែកាបអុបទិកប្រកបដោយសុវត្ថិភាព និងជឿទុកចិត្តឱ្យបានដល់គ្រប់ខេត្ត ដើម្បីពង្រីកវិសាលភាព និងរក្សានិរន្តរភាពនៃសេវាបច្ចេកវិទ្យាព័ត៌មានគមនាគមន៍ ។ បន្តអភិវឌ្ឍប្រព័ន្ធរដ្ឋបាលគ្រប់គ្រងអេឡិចត្រូនិច ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជំរុញការបណ្តុះបណ្តាលមន្ត្រីរាជការ សិស្ស និស្សិត លើវិស័យបច្ចេកវិទ្យាព័ត៌មានគមនាគមន៍។ បង្កើនវិសាលភាព និងគុណភាព នៃបណ្តាញផ្សព្វផ្សាយ ទាំងការផ្សាយក្នុងប្រទេស និងទៅក្រៅប្រទេស។

### អភិវឌ្ឍន៍ជនបទ

**៤៦.** ខិតខំធ្វើឱ្យកាន់តែប្រសើរឡើងនូវប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធជនបទ តាមរយៈការបន្តកសាងផ្លូវជនបទ ការរៀបចំឱ្យមានដំណើរការនៃប្រព័ន្ធគ្រប់គ្រង និងថែទាំផ្លូវជនបទដោយមានការចូលរួមរបស់

សហគមន៍មូលដ្ឋានជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ ជាពិសេសការកែលម្អផ្លូវជនបទជាជំហានៗ ពីផ្លូវក្រាលក្រួសក្រហម មកជាផ្លូវក្រាលកៅស៊ូ ឬផ្លូវបេតុង។ ខិតខំសម្រេចគោលដៅឆ្នាំ ២០១៨ ប្រជាពលរដ្ឋនៅជនបទចំនួន ៦០% នឹងបានទទួលសេវាផ្គត់ផ្គង់ទឹកស្អាតហើយនៅឆ្នាំ២០២៥ ប្រជាពលរដ្ឋគ្រប់រូបដែលរស់នៅក្នុងសហគមន៍ជនបទ ត្រូវមានសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យគ្រប់គ្រាន់ ព្រមទាំងរស់នៅក្នុងបរិស្ថានដែលមានអនាម័យប្រកបដោយនិរន្តរភាព។

**៤៧.** អភិវឌ្ឍសេដ្ឋកិច្ចជនបទ ដើម្បីកែលម្អ លើកកម្ពស់ជីវភាពប្រជាជននៅជនបទ និងកាត់បន្ថយការធ្វើចំណាកស្រុកស្វែងរកការងារ តាមរយៈការជំរុញវិស័យឥណទានជនបទដើម្បីផ្តល់សេវាប្រាក់កម្ចីដែលមានអត្រាការប្រាក់សមរម្យជូនប្រជាជននៅជនបទ ការបង្កើតកម្មវិធីបណ្តុះបណ្តាលជំនាញមូលដ្ឋាន ការជំរុញការអភិវឌ្ឍសិប្បកម្ម សហគ្រាស និងមុខជំនួញខ្នាតគ្រួសារ ខ្នាតតូច និងមធ្យម ដោយយកចិត្តទុកដាក់ផ្តល់បច្ចេកទេសជំនាញ និងការយល់ដឹងអំពីការបង្កើតមុខរបរ ព្រមទាំងការខិតខំពង្រីកទីផ្សារសម្រាប់ផលិតផលជនបទ។

**៤៨.** អភិវឌ្ឍតំបន់ដែលមានជនជាតិដើមភាគតិចរស់នៅឱ្យមានការរីកចម្រើនខាងសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ធានាសិទ្ធិពេញលេញរបស់បងប្អូនជនជាតិដើមភាគតិចក្នុងការចូលរួមធ្វើសេចក្តីសម្រេចនានា ដើម្បីកសាងគោលនយោបាយជាតិ សិទ្ធិទទួលបាននូវការការពារដោយច្បាប់ និងវិធានការសង្គមនានាដែលឆ្លើយតបទៅនឹងតម្រូវការចាំបាច់សម្រាប់ការរស់នៅប្រកបដោយភាពថ្លៃថ្នូរ ព្រមទាំងការគោរពចំពោះទំនៀមទម្លាប់ ប្រពៃណីល្អ និងភាសារបស់បងប្អូនជនជាតិ។

**ពាណិជ្ជកម្ម**

**៤៩.** បន្តជំរុញការអភិវឌ្ឍវិស័យពាណិជ្ជកម្ម តាមរយៈការធ្វើពិពិធកម្មទីផ្សារនាំចេញ និងការបង្កើនល្បឿនសមាហរណកម្មនៅក្នុងក្របខណ្ឌពាណិជ្ជកម្មសេរីសំខាន់ៗនៅក្នុងតំបន់ និងពិភពលោក ជាពិសេសបណ្តាប្រទេសក្នុងសមាគមអាស៊ានស្របតាមទិសដៅធ្វើឱ្យសម្រេចសហគមន៍អាស៊ានឆ្នាំ ២០១៥ និងបណ្តាប្រទេសជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក។ ឆ្លងតាមការអនុវត្តទិសដៅនេះ កម្ពុជានឹងទទួលបានអត្ថប្រយោជន៍សម្រាប់ការជំរុញកំណើនសេដ្ឋកិច្ច និងផ្តល់ឱកាសដល់កម្ពុជាក្នុងការរួមចំណែកកសាងគោលនយោបាយសេដ្ឋកិច្ចតំបន់ និងពិភពលោក ដើម្បីឱ្យការធ្វើពាណិជ្ជកម្មក្នុងតំបន់ និងពិភពលោកមានលក្ខណៈយុត្តិធម៌ សមធម៌ និងតម្លាភាព។

**៥០.** បន្តពង្រីកទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិ ដើម្បីផ្សារភ្ជាប់ទីផ្សារក្នុងប្រទេសជាមួយនឹងទីផ្សារក្រៅប្រទេស។ លើកកម្ពស់ការអភិវឌ្ឍសមត្ថភាពផលិត ផ្គត់ផ្គង់ ជំរុញការវិនិយោគ និងការនាំចេញទំនិញ

ដោយផ្តោតលើការបង្កើនគុណភាពផលិតផលក្នុងស្រុក ការបង្កើតបន្ថែមមុខរបរ និងមុខទំនិញថ្មីៗសម្រាប់នាំចេញ សំដៅរក្សាលំនឹងនៃជញ្ជីងពាណិជ្ជកម្ម បញ្ចៀសវិបត្តិទីផ្សារ ដោះស្រាយការងារ និងបង្កើនចំណូលរបស់ប្រជាពលរដ្ឋ។

**៥១.** រក្សាស្ថិរភាពថ្លៃទំនិញនៅលើទីផ្សារ បន្តធ្វើកិច្ចអន្តរាគមន៍លើទីផ្សារ ជាពិសេសចំពោះបណ្តាមុខទំនិញជាយុទ្ធសាស្ត្រ ដូចជា ស្រូវ អង្ករ ប្រេងឥន្ធនៈ អគ្គិសនី ទឹក និងបណ្តាមុខទំនិញផ្សេងៗទៀត ដែលត្រូវការប្រើប្រាស់ចាំបាច់សម្រាប់ជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ដោយចាត់វិធានការរាំងខ្ទប់បាតុភាពស្តុកទំនិញលក់ដំឡើងថ្លៃ ឬការលក់បំបោងថ្លៃ ដែលនាំឱ្យប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ បង្កលក្ខណៈងាយស្រួលឱ្យផលិតផល និងទំនិញធ្វើចរាចរបានដោយសេរីនៅគ្រប់ទីកន្លែង ដោយឈរលើគោលការណ៍ប្រកួតប្រជែងដោយស្មើភាព តាមថ្លៃទីផ្សារសេរី ជាពិសេសយកចិត្តទុកដាក់ការពារថ្លៃទំនិញកសិផលរបស់ប្រជាកសិករ និងជំនះបាតុភាពដែលនាំឱ្យកកស្ទះទំនិញកសិផល ការបន្ទាបបង្អាប់ថ្លៃកសិផល និងការរាំងស្ទះការដឹកជញ្ជូន។

**៥២.** ខិតខំរក្សាទីផ្សារដែលមានស្រាប់ និងបន្តចរចាបើកច្រកទីផ្សារជាមួយប្រទេសជាដៃគូពាណិជ្ជកម្មនានា ដើម្បីជំរុញឱ្យទំនិញ និងសេវារបស់កម្ពុជាដណ្តើមបានទីផ្សារកាន់តែទូលំទូលាយថែមទៀត។ ចូលរួមយ៉ាងសកម្មជាមួយបណ្តាប្រទេសក្នុងសមាគមអាស៊ាន ក្នុងការបង្កើតតំបន់ពាណិជ្ជកម្មសេរីជាមួយបណ្តាប្រទេសធំៗ ក្នុងពិភពលោក ដើម្បីពង្រីកទីផ្សារឱ្យបានជាអតិបរមា ។ ព្រមជាមួយនោះខិតខំពង្រឹង និងពង្រីកលក្ខណសម្បត្តិនានា សំដៅពង្រឹងសមត្ថភាពប្រកួតប្រជែងរបស់កម្ពុជានៅក្នុងទីផ្សារក្រៅប្រទេស។

**៥៣.** ការពារ លើកតម្កើងកម្មសិទ្ធិបញ្ញា ដែលជាប្រភេទកម្មសិទ្ធិ ឬ ទ្រព្យសម្បត្តិមួយដ៏មានតម្លៃ ដូចជា តម្លៃនៃទ្រព្យសម្បត្តិខាងបញ្ញាដែលទាក់ទងនឹងស្នាដៃតក្កកម្ម ការរកឃើញថ្មីនៃវិទ្យាសាស្ត្រ ការអភិវឌ្ឍបច្ចេកវិទ្យា គំនូសឧស្សាហកម្ម ម៉ាក និងពាណិជ្ជនាម ជាដើម។ លើកស្ទួយផលិតផលសម្គាល់ភូមិសាស្ត្រ ផលិតផលដែលបង្ហាញនូវមរតកវប្បធម៌ប្រពៃណីដែលជាស្នាដៃរបស់ផលិតករខ្មែរ ។ពង្រឹងការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញ និងសេវា ទប់ស្កាត់សកម្មភាពប្រកួតប្រជែងមិនស្មោះត្រង់ រាំងស្កាត់ការផលិត ការចែកចាយផលិតផលក្លែងក្លាយ ផលិតផលគ្មានគុណភាព ឬខូចគុណភាព ដើម្បីការពារផលប្រយោជន៍របស់ធុរជន វិនិយោគិន លើកទឹកចិត្តពាណិជ្ជករ ផលិតករឱ្យធ្វើប្រតិបត្តិការពាណិជ្ជកម្មដោយស្មើភាព និងការពារផលប្រយោជន៍របស់ប្រជាពលរដ្ឋដែលជាអ្នកប្រើប្រាស់ផលិតផល ទំនិញ ឬសេវានានា ។ ទប់ស្កាត់ការនាំចូលទំនិញប្រើប្រាស់រួចដែលប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថាន។

**៥៤.** បន្តជំរុញចលនា "ភូមិមួយ ផលិតផលមួយ" ដោយឈរលើគោលការណ៍បីយ៉ាងគឺ : ជំរុញឱ្យប្រជាជនផលិតស្របតាមលក្ខខណ្ឌភូមិសាស្ត្រ និងលក្ខខណ្ឌទីផ្សារក្នុងប្រទេស និងក្រៅប្រទេស , ផលិតឱ្យ

បានច្រើន ផលិតមានគុណភាពល្អ លក់ឱ្យដាច់ ហើយបានថ្លៃខ្ពស់ និងប្រើប្រាស់គំនិតច្នៃប្រឌិត ទេពកោសល្យ ភាពប៉ិនប្រសប់របស់ប្រជាជនតាមមូលដ្ឋាន ដែលនឹងជួយបង្កើតមុខរបរបន្ថែម រួមចំណែកបង្កើនចំណូល លើកកម្ពស់កម្រិតជីវភាពរស់នៅ។

## ការអភិវឌ្ឍវិស័យឯកជន និងការទាក់ទាញការវិនិយោគ

**៥៥**-គណបក្សប្រជាជនកម្ពុជា ចាត់ទុកវិស័យឯកជនជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ច។ ក្នុងន័យនេះ ការទាក់ទាញវិនិយោគផ្ទាល់ពីបរទេស ការជំរុញការវិនិយោគក្នុងស្រុក ជាពិសេសតាមរយៈការលើកកម្ពស់សហគ្រាសធុនតូច និងមធ្យម និងការជំរុញសហគ្រិនភាពក្នុងប្រទេស គឺជាកម្លាំងចលករក្នុងការបង្កើនល្បឿនអភិវឌ្ឍន៍ ពិពិធកម្មសេដ្ឋកិច្ច និងការបង្កើតការងារ។ លើសពីនេះ វិស័យឯកជនក៏ត្រូវចូលរួមទទួលខុសត្រូវផ្នែកសង្គមផងដែរ ដើម្បីធានានិរន្តរភាពនៃការអភិវឌ្ឍ។ ការកសាងអភិបាលកិច្ចសាជីវកម្មល្អជាប្រការចាំបាច់សម្រាប់ការប្រកួតប្រជែងផង សម្រាប់ភាពរឹងមាំ និងភាពរីកដុះដាលនៃវិស័យឯកជនខ្លួនឯងផង ព្រមទាំងសម្រាប់ពង្រឹងវប្បធម៌គណនេយ្យភាពចំពោះសង្គមផង ជាពិសេសតាមរយៈការបំពេញកាតព្វកិច្ចពន្ធ និងអាករ ។ អាស្រ័យហេតុនេះ ការខិតខំធ្វើឱ្យបរិស្ថានវិនិយោគ និងធុរកិច្ចនៅកម្ពុជាកាន់តែមានភាពអំណោយផល និងល្អប្រសើរ ព្រមទាំងធ្វើឱ្យកម្ពុជាក្លាយជាគោលដៅវិនិយោគមួយ ដែលមានភាពកាន់តែទាក់ទាញនៅក្នុងតំបន់ដែលនឹងបង្កើនបាននូវភាពប្រកួតប្រជែង និងផលិតភាពកាន់តែខ្ពស់សម្រាប់កម្ពុជានោះ គឺជាទិសដៅដ៏មានសារៈសំខាន់ចាំបាច់បំផុត។

**៥៦**- បន្តពង្រឹងអភិក្រមបើកចំហសម្រាប់ការអភិវឌ្ឍវិស័យឯកជន និងការទាក់ទាញវិនិយោគ សំដៅពង្រីកច្រកចូលទៅកាន់ទីផ្សារតំបន់ និងអន្តរជាតិ ។ រៀបចំឱ្យកាន់តែប្រសើរឡើងនូវរបបវិនិយោគឯកជន ដើម្បីផ្តល់ការលើកទឹកចិត្តសមស្រប និងចំគោលដៅដែលឆ្លើយតបទៅនឹងសំណូមពរនៃការអភិវឌ្ឍរយៈពេលវែង ។ ដើម្បីធានាបរិស្ថានវិនិយោគ និងធុរកិច្ចប្រកបដោយភាពអំណោយផល សម្រាប់ទទួលការវិនិយោគទាំងក្នុងប្រទេស និងពីក្រៅប្រទេស បណ្តាវិធានការសំខាន់ៗ និងត្រូវបានពង្រឹងថែមទៀត ដែលផ្តោតលើការធានាស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ការធានាស្ថិរភាព និងភាពគត់មត់នៃបរិស្ថានម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ការសម្រួលពាណិជ្ជកម្ម និងការសម្រួលធុរកិច្ច ជាអាទិ៍ ការកាត់បន្ថយការិយាធិបតេយ្យ ការអនុវត្តយន្តការច្រកចេញចូលតែមួយ ការលុបបំបាត់ចំណាយក្រៅផ្លូវការ ជាដើម។ ទន្ទឹមនេះ បន្តជំរុញការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការអនុវត្តវិធានការនានាសំដៅកាត់បន្ថយថ្លៃដឹកជញ្ជូន និងថ្លៃអគ្គិសនី ព្រមទាំងការជំរុញការរៀបចំកម្មវិធីបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដែលឆ្លើយតបទៅនឹងតម្រូវការទីផ្សារ។

**ទេសចរណ៍**

**៥៧.** អភិវឌ្ឍវិស័យទេសចរណ៍កម្ពុជា ជាទេសចរណ៍វប្បធម៌ និងធម្មជាតិប្រកបដោយគុណភាព និងចីរភាព ដោយប្រកាន់ខ្ជាប់នូវទស្សនៈ "ការអភិវឌ្ឍបម្រើឱ្យការអភិរក្ស និងការអភិរក្សបម្រើឱ្យការអភិវឌ្ឍ" ដើម្បីចូលរួមទ្រទ្រង់កំណើនសេដ្ឋកិច្ច លើកស្ទួយជីវភាពរបស់ប្រជាជន និងរួមចំណែកយ៉ាងសំខាន់ដល់ការអភិវឌ្ឍសេដ្ឋកិច្ចបៃតងដែលជានិន្នាការរួមនៃពិភពលោកបច្ចុប្បន្ន។ ដំណើរការនេះ តម្រូវឱ្យអនុវត្តទន្ទឹមគ្នានូវការខិតខំបង្កើនសមត្ថភាពប្រកួតប្រជែង និងការធានានិរន្តរភាពដែលកើតចេញពីការអភិវឌ្ឍវិស័យទេសចរណ៍ ព្រមជាមួយនេះត្រូវចាប់យកឱ្យបាននូវកាលានុវត្តភាពថ្មីៗនៃការអភិវឌ្ឍទេសចរណ៍ក្នុងតំបន់ និងពិភពលោក ។ ខិតខំសម្រេចគោលដៅទទួលទេសចរមកពីក្រៅប្រទេសនៅឆ្នាំ ២០១៥ ប្រមាណ ៤.៥លាននាក់ ឆ្នាំ២០១៨ កើនដល់ ៦.១លាននាក់ រួមជាមួយទេសចរក្នុងស្រុកប្រមាណ ១០.៥ លាននាក់ ដែលអាចបង្កើតការងារដោយផ្ទាល់បានជិត ៧សែននាក់ ។

**៥៨.** ដើម្បីសម្រេចគោលដៅនេះ ត្រូវបង្កើនការអភិវឌ្ឍ អភិរក្ស ការពារ និងកែលម្អឱ្យបានសមស្របនូវទីកន្លែងដែលមានសម្បត្តិវប្បធម៌ និងធនធានធម្មជាតិដែលជាគោលដៅទេសចរណ៍របស់ជាតិ។ យកចិត្តទុកដាក់ការគ្រប់គ្រង និងអភិវឌ្ឍគោលដៅទេសចរណ៍សំខាន់ៗរបស់ជាតិប្រកបដោយស្មារតីទទួលខុសត្រូវ និងប្រុងប្រយ័ត្នខ្ពស់ ព្រមទាំងបន្តខិតខំជំរុញការវិនិយោគក្នុងវិស័យទេសចរណ៍ និងបង្កើតផលិតផលទេសចរណ៍ថ្មីៗប្រកបដោយគុណភាពបន្ថែមទៀត។ រាល់គុណតម្លៃនៃសម្បត្តិមរតក និងធនធានរបស់ជាតិត្រូវថែរក្សាឱ្យបានល្អ ដើម្បីទ្រទ្រង់ដល់សកម្មភាពទេសចរណ៍យូរអង្វែង សម្រាប់មនុស្សជំនាន់ក្រោយៗទៀត។

**៥៩.** គោរពតម្លៃរបស់ប្រជាជនមូលដ្ឋាន សហគមន៍នីមួយៗ និងជំរុញឱ្យមានការចែករំលែកបទពិសោធន៍ល្អៗប្រកបដោយគុណភាពដល់ភ្ញៀវទេសចរ និងប្រជាជនមូលដ្ឋាន ព្រមទាំងផ្តល់សេវាប្រកបដោយគុណភាព ដើម្បីបង្កើនកម្រិតនៃការពេញចិត្តរបស់ភ្ញៀវទេសចរក្នុងការទស្សនាកម្សាន្ត និងទាក់ទាញឱ្យមានការផ្សព្វផ្សាយបន្ត ព្រមទាំងការវិលត្រឡប់មកទស្សនាជាថ្មីទៀត។

**៦០.** ជំរុញឱ្យបណ្តាភាគីពាក់ព័ន្ធទទួលផលប្រយោជន៍ពីវិស័យទេសចរណ៍ប្រកបដោយសមធម៌ ពោលគឺ បង្កើនអត្ថប្រយោជន៍សេដ្ឋកិច្ចជាអតិបរមា កាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមាននៃវិស័យទេសចរណ៍មកលើសេដ្ឋកិច្ច សង្គម វប្បធម៌ និងបរិស្ថាន និងកាត់បន្ថយការធ្លះធ្លាយក្នុងវិស័យទេសចរណ៍ឱ្យនៅកាន់តែតិចគឺត្រឹម ១៥% នៅរយៈពេល ៥ឆ្នាំខាងមុខ។

**៦១.** ចូលរួមអនុវត្តទិសដៅអភិវឌ្ឍន៍បៃតង តាមរយៈការបន្តជំរុញចលនាប្រឡងប្រណាំងទីក្រុងស្អាត ទីក្រុងបៃតង រមណីយដ្ឋានស្អាត រមណីយដ្ឋានបៃតង និងការចាប់យកទស្សនទានថ្មីៗនៃភាពបៃតង និងភាពស្អាត ដោយបំផុសចលនា និងសកម្មភាពប្រើប្រាស់បច្ចេកវិទ្យាបៃតង ដូចជា ការប្រើប្រាស់អគ្គិសនីពីថាមពលកកើតឡើងវិញ ការបង្កើនអនាម័យ ការដាំដើមឈើជាដើម ។ លើមូលដ្ឋាននេះ នឹងកាន់តែលើកកម្ពស់បាននូវគុណភាពនៃផលិតផលទេសចរណ៍របស់កម្ពុជា។

**៦២.** ខិតខំរក្សាទីផ្សារទេសចរណ៍ដែលមានស្រាប់ និងពង្រីកទីផ្សារថ្មីៗទៀត ជាពិសេសទីផ្សារក្នុងតំបន់ បង្កើនការផ្សព្វផ្សាយទេសចរណ៍តាមគ្រប់រូបភាព ជំរុញការតភ្ជាប់ និងសម្រួលការធ្វើដំណើរទេសចរណ៍ក្នុងតំបន់ ព្រមទាំងពង្រឹងការធានាសន្តិសុខ សុវត្ថិភាពដល់ទេសចរ និងអ្នកដំណើរនៅគ្រប់ទីកន្លែង។ បង្កើនការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ទាំងរដ្ឋ ឯកជន ប្រជាជន និងដៃគូអភិវឌ្ឍន៍ ក្នុងការជំរុញវិស័យទេសចរណ៍កម្ពុជា។ បន្តយកចិត្តទុកដាក់ពង្រឹងពង្រីកបណ្តាសហគមន៍ទេសចរណ៍មូលដ្ឋាន ដើម្បីលើកទឹកចិត្តប្រជាជនចូលរួមអភិវឌ្ឍវិស័យទេសចរណ៍ ការពារបរិស្ថាន ការពារធនធានវប្បធម៌ និងធម្មជាតិ។

**បរិស្ថាន**

**៦៣.** ការថែរក្សា ការពារជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី ការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាពទាំងនៅដែនគោក ទាំងនៅដែនសមុទ្រ ដើម្បីជាប្រយោជន៍ដល់ប្រជាជនទូទៅទាំងពេលបច្ចុប្បន្ន និងអនាគត ការឆ្លើយតបចំពោះការអភិវឌ្ឍឧស្សាហកម្មដែលបញ្ចេញធាតុពុលកាន់តែច្រើន និងការប្រែប្រួលអាកាសធាតុជាសកលនៅពេលបច្ចុប្បន្ននេះ គឺជាអាទិភាពដ៏ចម្បង ដើម្បីធានាដល់ការលូតលាស់នៃសេដ្ឋកិច្ច សង្គម និងការលើកកម្ពស់សុខុមាលភាពសាធារណៈ។ គណបក្សនឹងបន្តបង្កើនកិច្ចការពារគុណភាពបរិស្ថាន និងអភិរក្សធនធានធម្មជាតិឱ្យមានចីរភាពក្នុងប្រព័ន្ធអេកូឡូស៊ី តាមរយៈជំរុញការអភិវឌ្ឍសេដ្ឋកិច្ចបៃតង ដោយមានការចូលរួមពីគ្រប់មជ្ឈដ្ឋាន ជាពិសេសការចូលរួមរបស់សហគមន៍នៅមូលដ្ឋាន ពង្រឹងស្ថាប័ន និងក្របខណ្ឌច្បាប់ដែលពាក់ព័ន្ធនឹងការការពារបរិស្ថាន បន្តធ្វើសមាហរណកម្មបរិស្ថាននៅក្នុងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម និងពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិលើវិស័យបរិស្ថាន ទាំងក្នុងក្របខណ្ឌតំបន់ និងអន្តរជាតិ។

**៦៤.** ពង្រឹងការអនុវត្តច្បាប់ស្តីពីបរិស្ថានសំដៅថែរក្សាតំបន់ការពារធម្មជាតិ ទប់ស្កាត់រាល់សកម្មភាពបំផ្លាញគុណភាពបរិស្ថាន និងបញ្ចៀសគ្រោះមហន្តរាយនានា។ យកចិត្តទុកដាក់វាយតម្លៃឱ្យបានម៉ត់ចត់នូវហេតុប៉ះពាល់បរិស្ថានក្នុងការអនុវត្តគម្រោងអភិវឌ្ឍន៍នានា ដើម្បីធានាការប្រើប្រាស់ធនធានធម្មជាតិសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ប្រកបដោយចីរភាព ។ ពង្រឹងការគ្រប់គ្រងជីវសម្បទានក្នុងតំបន់ប្រើប្រាស់

ដោយចីរភាពសម្រាប់គម្រោងវិនិយោគអភិវឌ្ឍន៍ សំដៅការពារ ទប់ស្កាត់ ការរុករានយកដីព្រៃនៃតំបន់ស្នូល និងតំបន់អភិរក្ស ហើយមួយផ្នែកទៀតជួយផ្តល់បច្ចេកទេសដល់ប្រជាសហគមន៍ដែលរស់នៅក្បែរនោះ។ ជំរុញការអភិវឌ្ឍទេសចរណ៍ធម្មជាតិ ដែលនឹងជួយដល់ការថែរក្សាបរិស្ថាន និងធនធានធម្មជាតិ។ បង្កើនការត្រួតពិនិត្យ និងកាត់បន្ថយការបំពុលបរិស្ថាន ដែលរួមមាន ការគ្រប់គ្រងសំណល់រឹង សារធាតុប្រកបដោយគ្រោះថ្នាក់ ការត្រួតពិនិត្យ និងបង្កើនគុណភាពខ្យល់ ការត្រួតពិនិត្យ និងទប់ស្កាត់ការបំពុលទឹក និងដី ព្រមទាំងការបំពុលសោតារម្មណ៍ និងចក្ខុអារម្មណ៍។

### ឃ. ការអភិវឌ្ឍវិស័យអប់រំ សុខាភិបាល ការងារ វប្បធម៌ និង សង្គមកិច្ច អប់រំ និងកីឡា

**៦៥.** កសាង និងអភិវឌ្ឍធនធានមនុស្សលើគ្រប់ផ្នែកប្រកបដោយគុណភាព និងមានគុណធម៌ល្អប្រពៃ ដែលឆ្លើយតបទៅនឹងសំណូមពរនៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ដើម្បីកសាងកម្ពុជាឱ្យក្លាយជាសង្គមរីកចម្រើនជឿនលឿន ដែលផ្អែកលើមូលដ្ឋានចំណេះដឹងលើគ្រប់វិស័យរួមទាំងខាងវិទ្យាសាស្ត្រ បច្ចេកទេស និងចំណេះធ្វើ ហើយដើរស្របជាមួយនឹងការរីកចម្រើននៃបណ្តាប្រទេសនៅក្នុងតំបន់ និងពិភពលោក។ បន្តលើកកម្ពស់គោលការណ៍ "អប់រំសម្រាប់ទាំងអស់គ្នា" តាមរយៈការធានានូវលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌ ដែលផ្តល់ឱកាសស្មើៗគ្នាដល់កុមារ និងយុវជនកម្ពុជាទាំងអស់បានទទួលការអប់រំមូលដ្ឋានក្នុងប្រព័ន្ធ និងការអប់រំក្រៅប្រព័ន្ធ។ ការអនុវត្តគោលការណ៍នេះ ត្រូវផ្សារភ្ជាប់នឹងការអប់រំមនសិការស្នេហាជាតិ ការអប់រំអំពីប្រវត្តិសាស្ត្រ ការអប់រំវប្បធម៌សន្តិភាព ការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស ការគោរពគោលការណ៍សេរីភាព ប្រជាធិបតេយ្យ និងយុត្តិធម៌សង្គម ប្រឆាំងនឹងអំពើហិង្សា ការប្រើប្រាស់គ្រឿងញៀន និងការរើសអើងគ្រប់រូបភាព។

**៦៦.** ដើម្បីសម្រេចគោលដៅនេះ គណបក្សនឹងបន្តជំរុញការកសាងសាលារៀនឱ្យដល់ភូមិ កាត់បន្ថយការចំណាយរបស់មាតាបិតាសិស្ស បង្កើនថវិកាចំណាយសម្រាប់គ្រឹះស្ថានសិក្សា ពង្រាយគ្រូបង្រៀនឱ្យដល់គ្រប់ទីកន្លែង ពង្រីកអន្តេវាសិកដ្ឋាន បំផុសចលនាជាតិ និងពង្រីកការចូលរួមពីផ្នែកឯកជន ព្រមទាំងដៃគូអភិវឌ្ឍន៍នានា ដើម្បីអភិវឌ្ឍវិស័យអប់រំ ។ បន្តកសាងអនុវិទ្យាល័យឱ្យបានគ្រប់ឃុំដែលនៅមិនទាន់មានអនុវិទ្យាល័យ។

**៦៧.** បង្កើនគុណភាព និងប្រសិទ្ធភាពនៃសេវាអប់រំនៅគ្រប់កម្រិតសិក្សា និងការបណ្តុះបណ្តាលបច្ចេកទេស និងមុខជំនាញ ទាំងក្នុងគ្រឹះស្ថានរដ្ឋ ទាំងគ្រឹះស្ថានឯកជនឱ្យស្របទៅតាមកម្រិតស្តង់ដារអន្តរជាតិ និងតម្រូវការអភិវឌ្ឍន៍របស់ប្រទេស តាមរយៈការពង្រឹងការងារបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន

ការកែលម្អកម្មវិធីសិក្សា ការធ្វើអធិការកិច្ច និងពង្រឹងសមត្ថភាពគ្រប់គ្រង ការលើកទឹកចិត្តគ្រូបង្រៀនក្នុងការបង្កើនសមត្ថភាពបង្រៀន ការពង្រឹងគុណភាពក្នុងការប្រឡងបញ្ចប់កម្រិតសិក្សានីមួយៗ ការសិក្សាភាសាបរទេសដែលចាំបាច់ ការកែលម្អលក្ខខណ្ឌនៃការសិក្សា ការបង្កើតបណ្ណាល័យ មន្ទីរពិសោធន៍ និងបង្កើនការផ្គត់ផ្គង់សម្ភារៈសិក្សាជាដើម។ ព្រមជាមួយនោះ បន្តអភិវឌ្ឍស្ថាប័ន និងកសាងសមត្ថភាពរបស់មន្ត្រីអប់រំ ដោយបន្តកសាងច្បាប់ និងលិខិតបទដ្ឋាននានា ដែលពាក់ព័ន្ធវិស័យអប់រំ ពង្រឹងរចនាសម្ព័ន្ធការងារ និងបណ្តុះបណ្តាលជំនាញដល់មន្ត្រីអប់រំសំដៅធានាអភិបាលកិច្ចល្អនៅគ្រប់ថ្នាក់។

**៦៨.** អភិវឌ្ឍវិស័យកីឡា រួមទាំងកីឡាជនពិការ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិឱ្យមានការរីកចម្រើនស្របជាមួយនឹងការរីកចម្រើននៃវិស័យកីឡាក្នុងតំបន់ ដោយពង្រឹងការអនុវត្តគោលនយោបាយជាតិអភិវឌ្ឍវិស័យអប់រំកាយ និងកីឡាឱ្យមានប្រសិទ្ធភាពខ្ពស់ សំដៅរួមចំណែកដល់ការលើកកម្ពស់សុខភាពប្រជាជន ពង្រឹងសាមគ្គីភាព និងត្រៀមលក្ខណសម្បត្តិឱ្យបានល្អ ដើម្បីចូលរួម និងទទួលរៀបចំព្រឹត្តិការណ៍កីឡាធំៗ ជាលក្ខណៈអន្តរជាតិនានានៅពេលខាងមុខ ដូចជា អាស៊ានហ្គេមជាដើម ។

## សុខាភិបាល

**៦៩.** អភិវឌ្ឍវិស័យសុខាភិបាល សំដៅធ្វើឱ្យកាន់តែប្រសើរឡើងនូវសុខភាពប្រជាជន ដែលជាមូលដ្ឋានគន្លឹះមួយនៃការអភិវឌ្ឍធនធានមនុស្ស និងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម តាមរយៈ ការផ្តល់សេវាសុខាភិបាលប្រកបដោយប្រសិទ្ធភាព គុណភាព សមធម៌ និងមាននិរន្តរភាពដល់ប្រជាជនទូទៅ ពិសេសប្រជាជនក្រីក្រងាយរងគ្រោះ និងប្រជាជនរស់នៅតំបន់ជនបទ ។ សម្រាប់រយៈពេលមធ្យមបន្តទៅមុខទៀត ការខិតខំនៃវិស័យនេះមានគោលដៅកាត់បន្ថយឱ្យបានជាអតិបរមានូវការស្លាប់របស់មាតា ទារក និងកុមារ កាត់បន្ថយការឈឺ និងស្លាប់ដោយសារជំងឺឆ្លង និងជំងឺមិនឆ្លងរ៉ាំរ៉ៃ ព្រមទាំងការពង្រឹង និងពង្រីកនូវប្រព័ន្ធសុខាភិបាលឱ្យបានកាន់តែប្រសើរឡើង។ ដើម្បីសម្រេចគោលដៅនេះ គណបក្សនឹងផ្តោតលើការបន្តជំរុញអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់បណ្តាកម្មវិធីសំខាន់ៗ រួមមាន :

- កម្មវិធីសុខភាពបន្តពូជ សុខភាពមាតា ទារក និងកុមារ អាហារូបត្ថម្ភ និងការអប់រំសុខភាព។ ក្នុងនោះខិតខំបង្កើនអត្រាគ្របដណ្តប់នៃការផ្តល់ថ្នាំបង្ការគ្រប់មុខវ៉ាក់សាំងដល់កុមារ រួមទាំងការបញ្ចូលវ៉ាក់សាំងថ្មី និងទប់ស្កាត់មិនឱ្យកើតមានតទៅទៀតជំងឺកញ្ជ្រិល និងជំងឺតេតាណូសលើទារក ។

- កម្មវិធីប្រយុទ្ធជំងឺឆ្លង ជាពិសេសជំងឺអេដស៍ របេង គ្រុនចាញ់ គ្រុនឈាម និងជំងឺមិនឆ្លងរ៉ាំរ៉ៃ ក្នុងនោះខិតខំលុបបំបាត់ជំងឺគ្រុនចាញ់ឱ្យបានទាំងស្រុងនៅត្រឹមឆ្នាំ ២០២៥ ព្រមទាំងយកចិត្តទុកដាក់ព្យាបាលអ្នកប្រើប្រាស់សារធាតុញៀន។

- និងកម្មវិធីពង្រឹង និងពង្រីកប្រព័ន្ធសុខាភិបាលនៅគ្រប់ថ្នាក់ប្រកបដោយវិជ្ជាជីវៈ ។

**៧០.** ពង្រីកវិសាលភាពនៃសេវាសុខាភិបាលសាធារណៈ ឱ្យកាន់តែខិតជិតប្រជាជន ដោយបន្តពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្តនៃវិស័យនេះ ដូចជា ការសង់អគារមន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព ប៉ុស្តិ៍សុខភាព និងបង្កើតបន្ទប់រង់ចាំឱ្យបានច្រើនថែមទៀត ពង្រីកសកម្មភាពចុះផ្តល់សេវាសុខភាពតាមភូមិ ឃុំ ពង្រឹងយន្តការលើកលែងការបង់ថ្លៃសេវាពិនិត្យ និងព្យាបាលជំងឺសម្រាប់ប្រជាជនក្រីក្រ តាមរយៈការពង្រីកមូលនិធិសមធម៌ ការបង់ថ្លៃជួស ប្រព័ន្ធធានារ៉ាប់រងសុខភាពតាមសហគមន៍ និងរបបសន្តិសុខសង្គម ។ ពង្រឹងការផ្គត់ផ្គង់ឱសថឱ្យបានដល់គោលដៅតាមរបបកំណត់ក្នុងថវិកាប្រចាំឆ្នាំ ។

**៧១.** បង្កើនការវិនិយោគលើឧបករណ៍បរិក្ខារពេទ្យ និងបច្ចេកវិទ្យាទំនើប នៅមន្ទីរពេទ្យបង្អែកថ្នាក់ជាតិ និងខេត្ត ។ ពង្រឹងសមត្ថភាពជំនាញ និងក្រមសីលធម៌វិជ្ជាជីវៈរបស់មន្ត្រីបុគ្គលិកសុខាភិបាលគ្រប់ថ្នាក់ ដើម្បីផ្តល់សេវាជូនប្រជាជនប្រកបដោយភាពថ្លៃថ្នូរ រាក់ទាក់ យកចិត្តទុកដាក់ពិនិត្យ និងព្យាបាលអ្នកជំងឺគ្រប់រូបដោយគ្មានការរើសអើង ។

**៧២.** ពង្រឹងការគ្រប់គ្រងវិស័យឯកជន ដើម្បីឈានទៅលុបបំបាត់ឱសថក្លែងក្លាយ សេវាឯកជនខុសច្បាប់ និងធានាការប្រកបអាជីវកម្ម សេវាកម្មឱសថ និងសេវាសុខភាពឱ្យប្រព្រឹត្តទៅក្រោមលក្ខខណ្ឌច្បាប់ ។ បន្តលើកកម្ពស់ការចូលរួមរបស់សហគមន៍ និងភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជនដើម្បីបង្កើនការវិនិយោគក្នុងវិស័យសុខាភិបាល ទាំងផ្នែកហេដ្ឋារចនាសម្ព័ន្ធ ធនធានមនុស្ស ការផ្តល់សេវាសុខភាព និងការងារស្រាវជ្រាវជាដើម ព្រមទាំងរួមចំណែកពង្រឹងអន្តរាគមន៍សុខភាពសាធារណៈ ។

## ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

**៧៣.** អភិវឌ្ឍវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលតម្រង់ទិសលើការធ្វើឱ្យប្រជាពលរដ្ឋមានការងារ មុខរបរបានសមរម្យ ត្រឹមត្រូវ និងថ្លៃថ្នូរ ការការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់និយោជក និងកម្មករនិយោជិត ព្រមទាំងការកសាង និងលើកកម្ពស់សមត្ថភាពបច្ចេកទេស និងវិជ្ជាជីវៈឱ្យរីកចម្រើនស្របតាមបទដ្ឋានអន្តរជាតិ ។

បន្តលើកកម្ពស់លក្ខខណ្ឌការងារឱ្យបានកាន់តែប្រសើរឡើង ដោយពង្រឹងការអនុវត្តច្បាប់ស្តីពីការងារ បទដ្ឋានគតិយុត្តិនានា និងអនុសញ្ញាអន្តរជាតិខាងការងារ ។ បន្តពង្រឹងការអនុវត្តសេរីភាពសហជីព និងអង្គការវិជ្ជាជីវៈ ប្រឆាំងការរើសអើងចំពោះសហជីព និងអង្គការវិជ្ជាជីវៈ ជំរុញការកសាងច្បាប់ស្តីពីសហជីព និងច្បាប់ស្តីពីការបង្កើតតុលាការការងារ ។ ពង្រីកសុខដុមនីយកម្មក្នុងទំនាក់ទំនងវិជ្ជាជីវៈរវាងកម្មករនិយោជិត និងនិយោជក ព្រមទាំងពង្រឹងប្រព័ន្ធសុខភាព និងសុវត្ថិភាពការងារនៅតាមសហគ្រាស គ្រឹះស្ថាន

ឱ្យបានល្អប្រសើរ។ បន្តជំរុញការដំឡើងប្រាក់ឈ្នួល ការផ្តល់ប្រាក់ឧបត្ថម្ភ និងប្រាក់អត្ថប្រយោជន៍នានាដល់កម្មករនិយោជិត។ ខិតខំធ្វើឱ្យមានតុល្យភាពរវាងតម្រូវការ និងការផ្គត់ផ្គង់នៅក្នុងទីផ្សារពលកម្ម។ យកចិត្តទុកដាក់ទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារក្រោមអាយុកំណត់នៅតាមសហគ្រាស ។

**៧៤.** រៀបចំគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ស្របទៅនឹងការវិវឌ្ឍនៃសេដ្ឋកិច្ច សង្គម។ ពង្រឹងប្រព័ន្ធផ្សព្វផ្សាយ និងយន្តការសេវារកការងារធ្វើស្របច្បាប់សម្រាប់ពលករកម្ពុជាទាំងនៅក្នុងប្រទេស និងទៅក្រៅប្រទេស ទន្ទឹមនេះយកចិត្តទុកដាក់រក្សាតុល្យភាពកម្លាំងពលកម្មសម្រាប់ទីផ្សារការងារក្នុងស្រុក។ បង្កើនការការពារពលករខ្មែរដែលត្រូវបានបញ្ជូនទៅធ្វើការនៅបរទេស។ គ្រប់គ្រងកម្លាំងពលករបរទេសដែលធ្វើការនៅក្នុងព្រះរាជាណាចក្រកម្ពុជាស្របតាមច្បាប់ជាតិ និងគោលការណ៍សមាហរណកម្មរបស់សមាគមអាស៊ាន។

**៧៥.** ជំរុញការអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមច្បាប់ស្តីពីការងារ ក្នុងនោះរួមមាន : ការបន្តពង្រឹង និងពង្រីករបបធានារ៉ាប់រងហានិភ័យការងារឱ្យបានគ្របដណ្តប់ទូទាំងប្រទេស ការដាក់ឱ្យដំណើរការរបបធានារ៉ាប់រងសុខភាពសម្រាប់កម្មករ និយោជិត និងគ្រួសារក្នុងបន្ទុក ក្នុងឆ្នាំ ២០១៣ និងការដាក់ឱ្យដំណើរការរបបប្រាក់សោធននិវត្តន៍សម្រាប់កម្មករនិយោជិតក្នុងវិស័យឯកជនឱ្យទទួលបានរបបប្រាក់សោធននិវត្តន៍ដូចមន្ត្រីរាជការដែរ ចាប់ពីឆ្នាំ ២០១៥។

**៧៦.** អភិវឌ្ឍធនធានមនុស្សលើផ្នែកបច្ចេកទេស ឱ្យឆ្លើយតបទៅនឹងសំណូមពរនៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ដោយជំរុញការអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ប្រកបដោយគុណភាពប្រសិទ្ធភាព និងស្របតាមតម្រូវការនៃទីផ្សារការងារ។ ពង្រីកបណ្តាលក្ខខណ្ឌអនុគ្រោះឱ្យប្រជាជនជាពិសេសស្រទាប់ យុវវ័យបានទទួលការបណ្តុះបណ្តាលជំនាញរយៈពេលខ្លី ឬមធ្យមប្រកបដោយសមធម៌តាមគ្រប់រូបភាព ដើម្បីមានលទ្ធភាពបង្កើតមុខរបរដោយខ្លួនឯង ឬរកការងារធ្វើនៅតាមរោងចក្រសហគ្រាស ការដ្ឋាននានា ឬទៅធ្វើការងារដោយស្របច្បាប់នៅក្រៅប្រទេស ។

**៧៧.** សម្របសម្រួលឱ្យស៊ីចង្វាក់គ្នារវាងវិស័យអប់រំ និងវិស័យបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។ ជំរុញការកសាងគ្រឹះស្ថានអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឱ្យមាននៅគ្រប់ខេត្ត ដែលអាចផ្តល់ការបណ្តុះបណ្តាលនៅតាមសហគមន៍ ព្រមទាំងរួមចំណែកដល់ទិសដៅ "ភូមិមួយ ផលិតផលមួយ"។ ពង្រីកលទ្ធភាពបង្កើតអន្តេវាសិកដ្ឋាននៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈសម្រាប់សិស្ស និស្សិត សិក្ខាកាម ដែលមានទីលំនៅឆ្ងាយៗស្នាក់នៅ។ លើកទឹកចិត្តការចូលរួមនៃផ្នែកឯកជន និងអង្គការមិនមែនរដ្ឋាភិបាលក្នុងការពង្រីកកម្មវិធីបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឱ្យកាន់តែមានវិសាលភាពឆ្លើយតបទៅនឹងតម្រូវការនៃសង្គម ។

### វប្បធម៌ ជំនឿ សាសនា

**៧៨.** លើកកម្ពស់ការអភិរក្ស និងអភិវឌ្ឍវប្បធម៌ជាតិ ដើម្បីថែរក្សា ការពារបេតិកភណ្ឌវប្បធម៌ជាតិ ទាំងរូបី និងអរូបីឱ្យស្ថិតស្ថេរគង់វង្សយូរអង្វែង បង្កើតផលិតផលវប្បធម៌ឱ្យបានកាន់តែច្រើន ហើយចូលរួមសកម្មក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងកែលម្អជីវភាពប្រជាជនស្របតាមអត្ថន័យវប្បធម៌ជាសេដ្ឋកិច្ច ។ ដើម្បីសម្រេចគោលដៅនេះ គណបក្សនឹងបន្តផ្តោតលើសកម្មភាពសំខាន់ៗជាអាទិភាពគឺ ការថែរក្សា និងអភិវឌ្ឍតំបន់បេតិកភណ្ឌឱ្យមាននិរន្តរភាព ការថែទាំ និងអភិរក្សប្រាសាទបុរាណនានា ការជំរុញឱ្យកម្ពុជាក្លាយជាមជ្ឈមណ្ឌលមួយនៃការផ្សព្វផ្សាយសិល្បៈ ទស្សនីយភាព ផ្សព្វផ្សាយផលិតផលសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម ការពង្រីកសកម្មភាពវប្បធម៌លើគ្រប់ជំនាញ និងការខិតខំពង្រីកទីផ្សារវប្បធម៌ឱ្យកាន់តែបានទូលាយទាំងក្នុងប្រទេស និងក្រៅប្រទេសដែលនឹងជំរុញថែមទៀតដល់ផលិតកម្មវប្បធម៌ខ្មែរ ។ បង្កើនការអប់រំ ជាពិសេសការអប់រំស្រទាប់យុវជន និងកុមារឱ្យយល់ដឹងច្បាស់អំពីតម្លៃដ៏វិសេសវិសាលនៃវប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់ខ្មែរ ដែលជាអត្តសញ្ញាណរបស់ជាតិ ហើយចូលរួមថែរក្សា លើកតម្កើងអភិវឌ្ឍវប្បធម៌ជាតិ និងកាត់បន្ថយឥទ្ធិពលនៃវប្បធម៌អវិជ្ជមានពីបរទេស។

បង្កើនការផ្លាស់ប្តូរសកម្មភាពវប្បធម៌សិល្បៈជាមួយបណ្តាប្រជាជាតិ ដើម្បីសន្តិភាព សុខដុមនីយកម្ម និងអភិវឌ្ឍន៍ ។ ថែរក្សា និងអភិវឌ្ឍវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ល្អ និងភាសារបស់បងប្អូនជនជាតិដើមភាគតិច។

**៧៩.** គោរពសេរីភាពខាងជំនឿ និងសាសនា លើកស្ទួយព្រះពុទ្ធសាសនាដែលជាសាសនារបស់រដ្ឋ ជាពិសេសការបន្តពង្រឹង និងពង្រីកពុទ្ធិកសិក្សានៅគ្រប់កម្រិត ការបោះផ្សាយគម្ពីរដីកា ក្បួនច្បាប់នានា និងកិច្ចប្រតិបត្តិធម្មវិន័យ ទន្ទឹមនេះ គាំទ្រសកម្មភាពនៃសាសនាផ្សេងៗទៀតក្នុងសង្គម។ ពង្រឹងសុខដុមនីយកម្មរវាងសាសនិកនៃគ្រប់សាសនា ប្រឆាំងការរើសអើង បែងចែកក្នុងចំណោមប្រជាជនដែលបណ្តាលមកពីភាពខុសគ្នាខាងសាសនា សំដៅប្រែក្លាយសក្តានុពលរបស់សាសនាទាំងអស់ ទៅជាកម្លាំងជំរុញការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ពង្រឹងសន្តិភាព សាមគ្គីភាព ថែរក្សាប្រពៃណីជាតិ និងលើកកម្ពស់តម្លៃសីលធម៌។ រាំងស្កាត់ការយកសាសនាទៅធ្វើអាជីវកម្ម និងបង្កជាវិបត្តិសាសនា។

### សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

**៨០.** អភិវឌ្ឍវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាឱ្យកាន់តែមានវិសាលភាពទូលំទូលាយ រួមចំណែកធ្វើឱ្យសុខុមាលភាពរបស់ប្រជាជនមានស្ថានភាពកាន់តែប្រសើរឡើង ដោយមានសេវាសង្គមកិច្ចគ្រប់គ្រាន់សម្រាប់ជួយជនរងគ្រោះ និងជនងាយរងគ្រោះគ្រប់ប្រភេទ មានប្រព័ន្ធសន្តិសុខសង្គម

រឹងមាំ និងទូលំទូលាយសម្រាប់ធានារ៉ាប់រងចំពោះហានិភ័យសង្គមជាយថាហេតុ ហើយធ្វើឱ្យសេវាសង្គមកិច្ច កាន់តែនៅកៀកនឹងប្រជាជន ព្រមទាំងមានការចូលរួមដ៏សកម្មពីប្រជាជន ។

លើការងារអភិវឌ្ឍសុខុមាលភាពសង្គម គណបក្សនឹងជំរុញបង្កើនអន្តរាគមន៍សង្គមកិច្ច ដើម្បីជួយដល់ប្រជាជនក្រីក្រងាយរងគ្រោះ និងជនរងគ្រោះដោយគ្រោះមហន្តរាយផ្សេងៗ។ លើកកម្ពស់សន្តិសុខស្បៀង បន្តពង្រឹងពង្រីកកម្មវិធីសង្គ្រោះបន្ទាន់សម្រាប់ប្រជាជនក្រីក្រងាយរងគ្រោះ ទប់ស្កាត់ទុរគតភាព និងការធ្វើចំណាកស្រុកដោយប្រថុយប្រថាន។ ពង្រឹងកម្មវិធីដោះស្រាយបញ្ហាជនអនាថា ជំរុញការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស យកចិត្តទុកដាក់ធ្វើការអភិវឌ្ឍសហគមន៍ប្រជាជនក្រីក្រ ឱ្យទទួលបានកាលានុវត្តភាពសម្រាប់កែលម្អជីវភាព។ ខិតខំបង្កើតប្រព័ន្ធសន្តិសុខសង្គមឱ្យបានទូលំទូលាយ គ្របដណ្តប់គ្រប់ស្រទាប់ប្រជាជន និងគ្រប់មជ្ឈដ្ឋាន ធ្វើជាស្នូលនៃសំណាញ់សុវត្ថិភាពសង្គម និងជំរុញការអនុម័តច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ប្រជាជនកម្ពុជា។

**៨១-** លើកកម្ពស់ការអនុវត្តការងារយុវនីតិសម្បទា និងការអនុវត្តកម្មវិធីយុត្តិធម៌អនីតិជន ។ ពង្រឹងការព្យាបាល ស្តារនីតិសម្បទាសម្រាប់ជួយជនរងគ្រោះដែលប្រើប្រាស់បំពានសារធាតុញៀនតាមមណ្ឌល ព្រមជាមួយនោះ លើកទឹកចិត្ត ការព្យាបាល និងស្តារនីតិសម្បទាជនរងគ្រោះដែលប្រើប្រាស់បំពានសារធាតុញៀននៅតាមសហគមន៍ ។

**៨២-** បន្តអនុវត្តគោលនយោបាយជាតិចំពោះជនពិការ ជំរុញកិច្ចការពារលើកកម្ពស់សិទ្ធិសុខុមាលភាពជនពិការតាមអនុសញ្ញានៃអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការ និងការអនុវត្តច្បាប់ស្តីពីកិច្ចការពារលើកកម្ពស់សិទ្ធិជនពិការ ផ្តល់សេវាស្តារលទ្ធភាពពលកម្មដោយមិនបង់ថ្លៃសម្រាប់ជនពិការក្រីក្រ ពង្រីកសេវាសហគមន៍ អនុវត្តគោលនយោបាយឧបត្ថម្ភជនពិការក្រីក្រតាមសហគមន៍ និងបង្កើនការចូលរួមរបស់ជនពិការក្នុងគ្រប់សកម្មភាព។

បន្តអនុវត្តគោលនយោបាយជាតិសម្រាប់មនុស្សចាស់ ដោយយកចិត្តទុកដាក់ជំរុញនូវកម្មវិធីអភិវឌ្ឍន៍មនុស្សចាស់តាមសហគមន៍ និងកម្មវិធីថែទាំមនុស្សចាស់តាមគ្រួសារឱ្យបានកាន់តែប្រសើរ។ ពង្រឹងសកម្មភាពនៃសមាគមមនុស្សចាស់នៅតាមឃុំ សង្កាត់ លើកទឹកចិត្តចំពោះការបង្កើតកម្មវិធីមនុស្សធម៌នានា ដើម្បីជួយដល់ជនចាស់ជរា។ ជំរុញការរៀបចំ និងដំណើរការសេវាជនចាស់ជរា ដើម្បីបណ្តុះបណ្តាលភ្នាក់ងារផ្តល់សេវាថែទាំជនចាស់ជរា។

ពង្រឹងការអនុវត្តគោលនយោបាយជាតិចំពោះអតីតយុទ្ធជន និងគោលនយោបាយជាតិចំពោះអតីតមន្ត្រីរាជការស៊ីវិលឱ្យកាន់តែមានប្រសិទ្ធភាព ។ បន្តអនុវត្តនយោបាយរដ្ឋទទួលបន្ទុកបង់ប្រាក់ភាគទាន ៦% នៃ

ប្រាក់បៀវត្សជូនមន្ត្រីរាជការស៊ីវិល សម្រាប់ទ្រទ្រង់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល និងរដ្ឋបង់ប្រាក់ភាគទានតាមការកំណត់ជូនកងកម្លាំងប្រដាប់អាវុធសម្រាប់ទ្រទ្រង់បេឡាជាតិអតីតយុទ្ធជន ។ ពង្រឹងបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល បេឡាជាតិសម្រាប់អតីតយុទ្ធជន និងមូលនិធិជនពិការជាគ្រឹះស្ថានសាធារណៈរដ្ឋបាលដែលមានលក្ខណៈហិរញ្ញវត្ថុមិនមែនធនាគារ ជាគ្រឹះស្ថានសោធនសម្រាប់ផ្តល់សេវាសន្តិសុខសង្គមផង និងអនុវត្តយុទ្ធសាស្ត្រជាតិនៃវិស័យហិរញ្ញវត្ថុផង ។ បន្តអនុវត្តគោលនយោបាយផ្តល់សម្បទានដីសង្គមកិច្ច កសាងលំនៅស្ថានជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារដែលមានតម្រូវការពិតប្រាកដ ព្រមទាំងបង្កើតគម្រោងជាច្រើនថែមទៀតដើម្បីកែលម្អជីវភាពយោធិន និងអតីតយុទ្ធជន ។

**៨៣.** ពង្រឹងភាពជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ព្រមទាំងសប្បុរសជន ដើម្បីពង្រីកស្មារតីសាមគ្គីធម៌នៅក្នុងសង្គម កៀរគរប្រភពធនធាន ថវិកា សម្ភារៈ បច្ចេកទេស សម្រាប់បម្រើឱ្យសំណូមពរនៃការងារសង្គមកិច្ច និងការជួយដល់ជនក្រីក្រងាយរងគ្រោះ ។

### ស្ត្រី កុមារ និងយុវជន

**៨៤.** ពង្រឹងស្ថានភាព និងតួនាទីដ៏សំខាន់របស់ស្ត្រីក្នុងសង្គម លើកស្ទួយសីលធម៌ និងតម្លៃរបស់ស្ត្រីខ្មែរ លុបបំបាត់រាល់ទស្សនៈមើលស្រាលតួនាទីរបស់ស្ត្រី សំដៅលើកកម្ពស់ការចូលរួមរបស់ស្ត្រីឱ្យកាន់តែទូលំទូលាយ និងខ្លាំងក្លាថែមទៀតក្នុងការកសាង និងការពារមាតុភូមិ ។

បន្តលើកកម្ពស់សមធម៌យេនឌ័រ ជំរុញភាពអង់អាចរបស់ស្ត្រីនៅក្នុងសេដ្ឋកិច្ច ដោយជំរុញការបណ្តុះបណ្តាល បំពាក់បំប៉នជំនាញបច្ចេកទេស និងផ្តល់កាលានុវត្តភាពដល់ស្ត្រីក្នុងការពង្រីកមុខរបរ បង្កើនចំណូល និងកសាងសហគ្រិនភាព ។ បង្កើនឱកាសរៀនសូត្រសម្រាប់ស្ត្រី និងក្មេងស្រី ជាពិសេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ និងឧត្តមសិក្សា។ ពង្រីកលទ្ធភាពក្នុងការទទួលបានសេវាសុខាភិបាលប្រកបដោយគុណភាព សម្រាប់ស្ត្រី និងក្មេងស្រី ជាពិសេសនៅតាមតំបន់ជនបទ។ ជំរុញកម្មវិធីអប់រំសីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ សំដៅពង្រីកវប្បធម៌អហិង្សា ការកសាងគ្រួសារ និងសហគមន៍ប្រកបដោយសុភមង្គល។ ពង្រឹងការអនុវត្តច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ និងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ជាពិសេសការអនុវត្តផែនការជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ដើម្បីលុបបំបាត់នូវឥរិយាបថប្រើអំពើហិង្សាលើស្ត្រី។

**៨៥.** បន្តបង្កើនសមាមាត្រនៃការចូលរួមរបស់ស្ត្រីឱ្យបានកាន់តែច្រើនឡើងនៅក្នុងស្ថាប័នជាតិគ្រប់ថ្នាក់ ដើម្បីឱ្យស្ត្រីបានចូលរួមកាន់តែសកម្មក្នុងការធ្វើសេចក្តីសម្រេចនានា ការកសាងផែនការអភិវឌ្ឍន៍ និងអភិបាលកិច្ច ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

**៨៦.** ផ្តល់អាទិភាពលើការអភិវឌ្ឍសុខុមាលភាពកុមារឱ្យបានល្អប្រសើរ ដោយជំរុញការផ្សព្វផ្សាយ និងអនុវត្តយ៉ាងម៉ត់ចត់នូវអនុសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិកុមារ ជាពិសេសធានាឱ្យកុមារបានទទួលពិតប្រាកដនូវសិទ្ធិជាមូលដ្ឋានទាំងបួនរបស់កុមារ គឺ "សិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានការអភិវឌ្ឍ សិទ្ធិទទួលបានការការពារ និងសិទ្ធិចូលរួមរបស់កុមារ"។ បន្តខិតខំសម្រេចនូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់កម្ពុជាដែលពាក់ព័ន្ធនឹងកុមារ។ ពង្រឹងការអនុវត្តនយោបាយថែទាំជំនួសចំពោះកុមារ ការថែទាំកុមារតាមគ្រួសារ និងសហគមន៍ បង្កើនការគ្រប់គ្រង និងគុណភាពនៃការថែទាំកុមារនៅតាមមណ្ឌល ទាំងមណ្ឌលរដ្ឋ និងមណ្ឌលនៃអង្គការមិនមែនរដ្ឋាភិបាល។ អនុវត្តម៉ឺងម៉ាត់នូវអនុសញ្ញាអន្តរជាតិ និងច្បាប់ជាធរមាន ដើម្បីរកគ្រួសារល្អសម្រាប់កុមារនៅក្នុងប្រទេស និងអន្តរប្រទេស រាំងស្កាត់ការធ្វើអាជីវកម្មកុមារតាមគ្រប់រូបភាព។

**យុវជន**

**៨៧.** យុវជនជាសសរទ្រូងរបស់ជាតិទៅអនាគត ជាកម្លាំងបន្តវេនប្រកបដោយសក្តានុពលក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងការការពាររាល់សមិទ្ធផលសង្គម ។ ភាពរឹងមាំរបស់យុវជនកម្ពុជា ជាតំណាងឱ្យអនាគតដ៏រុងរឿងរបស់ជាតិ ។ គណបក្សប្រជាជនកម្ពុជាយកចិត្តទុកដាក់បន្តជំរុញការអភិវឌ្ឍយុវជនឱ្យមានការរីកចម្រើនគ្រប់ផ្នែកទាំងខាងចំណេះដឹង ចំណេះធ្វើ សុខភាព កាយសម្បទា និងមានសីលធម៌រស់នៅថ្លៃថ្នូរ ចៀសផុតពីអំពើអបាយមុខ និងអំពើហិង្សា ហើយប្តេជ្ញាឈ្នះក្នុងការបំពេញរាល់ភារកិច្ចរបស់ខ្លួន។

ដើម្បីសម្រេចគោលដៅនេះ គណបក្សបន្តលើកកម្ពស់ការអប់រំ និងបណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈ ចំណេះដឹងវិទ្យាសាស្ត្របច្ចេកទេស និងកម្មវិធីបំណិនជីវិតដល់យុវជន ជាពិសេសយុវជនពុំសូវមានលទ្ធភាព យុវជនងាយរងគ្រោះ និងយុវជនពិការ ឱ្យមានសមត្ថភាព និងកាលានុវត្តភាពក្នុងការបង្កើតមុខរបរ ឬស្វែងរកការងារធ្វើក្នុងទីផ្សារពលកម្មដែលកំពុងតែមានការរីកចម្រើន ។ បង្កើនការអប់រំ ការថែទាំ និងការផ្តល់សេវាសុខភាពប្រកបដោយគុណភាព និងសមធម៌ដល់យុវជន ពង្រីកសកម្មភាពសិល្បៈ កីឡាការកម្សាន្តសម្រាប់យុវជន សំដៅពង្រឹងកាយសម្បទា សុខភាព និងសាមគ្គីភាពក្នុងជួរយុវជន យុវនារី ។

ការពារសន្តិសុខ សុវត្ថិភាព និងយុត្តិធម៌សម្រាប់យុវជន យកចិត្តទុកដាក់បញ្ចូលតម្រូវការរបស់យុវជនទៅក្នុងផែនការអភិវឌ្ឍន៍គ្រប់កម្រិត ពង្រីកការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំ និងជំរុញការអនុវត្តជាជំហានៗនូវទិសដៅយុវភាវូបនីយកម្មក្នុងការផ្តល់ការទទួលខុសត្រូវ នៅគ្រប់លំដាប់ថ្នាក់ដល់យុវជន ដើម្បីឱ្យយុវជនកាន់តែពង្រីកបាននូវឱកាស និងសមត្ថភាពរបស់ខ្លួនក្នុងការអភិវឌ្ឍប្រទេស ។ លើកទឹកចិត្តពង្រឹងចលនាស្ម័គ្រចិត្តរបស់យុវជនចូលរួមក្នុងសកម្មភាពកសាងយុត្តិធម៌ក្នុងសង្គម ការទប់ស្កាត់បាតុភាពអសកម្មតាមសហគមន៍ និងក្នុងសកម្មភាពផ្សេងៗទៀត ដើម្បីបម្រើផលប្រយោជន៍ប្រជាជននៅតាមមូលដ្ឋានក៏ដូចផលប្រយោជន៍សាធារណៈ។

ជំរុញចលនាកាយរិទ្ធនៅតាមសាលាបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ រួមចំណែកបង្កលក្ខណៈឱ្យសមាជិកកាយរិទ្ធគ្រប់រូបក្លាយជាពលរដ្ឋដែលមានការរីកចម្រើនពេញលេញ ទាំងកាយសម្បទា ចំណេះដឹង និងបញ្ញាស្មារតី មានការទទួលខុសត្រូវចំពោះខ្លួនឯង ចំពោះគ្រួសារ និងសង្គម ហើយចូលរួមក្នុងសកម្មភាពនានា ដែលផ្តល់ប្រយោជន៍ដល់សហគមន៍ សង្គមជាតិ និងអន្តរជាតិ។

ជំរុញចលនាយុវជនកាកបាទក្រហម ដើម្បីពង្រឹងពង្រីកស្មារតីមនុស្សធម៌ឱ្យបានទូលំទូលាយក្នុងមហាជន តាមគោលការណ៍របស់កាកបាទក្រហម និងអឌ្ឍចន្ទក្រហមអន្តរជាតិ ព្រមទាំងចូលរួមក្នុងសកម្មភាពនានាដូចជា ការអប់រំយុវជនអំពីបញ្ហាសុខភាព អំពីសុវត្ថិភាពចរាចរណ៍ និងការរក្សាអនាម័យនៅតាមមូលដ្ឋានជាដើម។

*　　　*
*

កម្មវិធីនយោបាយរបស់គណបក្សប្រជាជនកម្ពុជា ដើម្បីកសាង និងការពារមាតុភូមិ ឆ្នាំ ២០១៣-២០១៨ ជាបញ្ញាញាណរបស់គណបក្សទាំងមូល ដែលត្រូវបានកសាងឡើងដោយផ្អែកលើរាល់សមិទ្ធផលដ៏ថ្លៃថ្លាបំផុតនៃសង្គមជាតិដែលបានសម្រេចក្នុងរយៈពេល ៣៤ឆ្នាំកន្លងមកនេះ ជាពិសេសលទ្ធផលនៃការអនុវត្តកម្មវិធីនយោបាយរបស់គណបក្សឆ្នាំ ២០០៨-២០១៣ ព្រមទាំងផ្អែកលើការវិវត្តជាក់ស្តែងនៃសភាពការណ៍ជាតិ និងអន្តរជាតិបច្ចុប្បន្ន និងបំណងប្រាថ្នាដ៏ពិសិដ្ឋរបស់ប្រជាជន ដើម្បីបន្តនាំកម្ពុជាឈានឡើងឆ្ពោះទៅកាន់ដំណាក់កាលរីកចម្រើនមួយថ្មីទៀតដ៏ខ្លាំងក្លារបស់ខ្លួន ប្រកបដោយកិត្តិយស និងសេចក្តីសង្ឃឹមជឿជាក់ចំពោះអនាគត ក្នុងឯករាជ្យ បូរណភាពទឹកដី ឯកភាព សន្តិភាព ប្រជាធិបតេយ្យ និងវិបុលភាព។

គណបក្សប្រជាជនកម្ពុជា សូមអំពាវនាវដល់ជនរួមជាតិនៅគ្រប់ទិសទី និងគ្រប់មជ្ឈដ្ឋានក្នុងសង្គម សូមផ្តល់ការគាំទ្រ និងចូលរួមអនុវត្តយ៉ាងសកម្មនូវកម្មវិធីនយោបាយនេះ ដើម្បីបន្តរួមគ្នាពុះពារជំនះរាល់ឧបសគ្គ និងការលំបាកទាំងឡាយក្នុងដំណើររីកចម្រើនរបស់ជាតិ ហើយបង្កើតឡើងនូវសមិទ្ធផលថ្មីៗទៀតកាន់តែធំធេងឡើង ក្នុងបុព្វហេតុកសាង អភិវឌ្ឍ និងការពារមាតុភូមិយើង ។

កម្មវិធីនយោបាយនេះ ត្រូវបានមហាសន្និបាតវិសាមញ្ញតំណាងទូទាំងប្រទេសរបស់គណបក្សប្រជាជនកម្ពុជាអនុម័តនាថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៣ ។